សាលាដំបូងខេត្តសៀមរាប

សំណុំរឿងព្រហ្មទណ្ឌលេខ ៤៣៧
ចុះថ្ងៃទី០១ ខែឧសភា ឆ្នាំ២០២១
សំណុំរឿងជំនុំជម្រះលេខ ១៣៨
ចុះថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០២២
សាលក្រមលេខ ៧៤ (ឆ)/៥៩១
ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០២៣

# ព្រះរាជាណាចក្រកម្ពុជា
# ជាតិ សាសនា ព្រះមហាក្សត្រ

## សាលក្រម
## តាងនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងខេត្តសៀមរាប

បានបើកសវនាការជាសាធារណៈនៅសាលាដំបូងខេត្តសៀមរាប
-កាលបរិច្ឆេទបើកសវនាការថ្ងៃទី០៩ ខែសីហា ឆ្នាំ២០២៣ ពេលរសៀល
-កាលបរិច្ឆេទប្រកាសសាលក្រមថ្ងៃទី៣០ ខែសីហា ឆ្នាំ២០២៣ ពេលរសៀល
ដោយមានសមាសភាពជំនុំជម្រះដូចខាងក្រោម៖

**ចៅក្រមជំនុំជម្រះ**

លោកស្រី [redacted] ជាប្រធានក្រុមប្រឹក្សាជំនុំជម្រះ
លោក [redacted] ជាក្រុមប្រឹក្សាជំនុំជម្រះ
លោក [redacted] ជាក្រុមប្រឹក្សាជំនុំជម្រះ

**តំណាងអយ្យការ**

លោកស្រី [redacted] ជាព្រះរាជអាជ្ញារង

**ក្រឡាបញ្ជីសវនាការ**

លោក [redacted] ជាក្រឡាបញ្ជី

លោក [redacted] ជាមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទឈ្មោះ [redacted] សេង ឈ្មោះ [redacted] សារិន ឈ្មោះ [redacted] សុគុណ ឈ្មោះ [redacted] សេរីវឌ្ឍ ឈ្មោះ [redacted] ឈុនឡេង ឈ្មោះ [redacted] សេរីរត្ន ឈ្មោះ [redacted] ឆៃគី និងឈ្មោះ [redacted] អ៊ិច ។

លោក [redacted] មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទឈ្មោះ [redacted] សេង ។

លោក [redacted] មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទឈ្មោះ [redacted] សេង ។

លោក [redacted] លោក [redacted] មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទឈ្មោះ [redacted] អ៊ិច ។

លោក [redacted] មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទឈ្មោះ [redacted] ស៊ុក ឈ្មោះ [redacted] សារិន ឈ្មោះ [redacted] សុគុណ ឈ្មោះ [redacted] សេរីវឌ្ឍ ឈ្មោះ [redacted] ឈុនឡេង ឈ្មោះ [redacted] សេរីរត្ន ឈ្មោះ [redacted] ឆៃគី និងឈ្មោះ [redacted] អ៊ិច ។

លោក [redacted] មេធាវីការពារក្ដីឲ្យដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] បឿប ឈ្មោះ [redacted] សឿត ឈ្មោះ [redacted] យ៉ា និងឈ្មោះ [redacted] សុវណ្ណ ។



Scanned with CamScanner

ដើម្បីជំនុំជម្រះសំណុំរឿងព្រហ្មទណ្ឌលេខ ៤៣៧ ចុះថ្ងៃទី០១ ខែឧសភា ឆ្នាំ២០២១ ដែលមាន៖

១-ជនជាប់ចោទឈ្មោះ [redacted] **សេខ** ភេទប្រុស កើតនៅថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ១៩៨០ ជនជាតិខ្មែរ មុខរបរកសិករ កម្រិតវប្បធម៌ថ្នាក់ទី៥ ទីកន្លែងកំណើតនៅ [redacted] ខេត្តសៀមរាបទីលំនៅបច្ចុប្បន្ននៅ [redacted] ខេត្តសៀមរាប ប្រពន្ធឈ្មោះ [redacted] ឡាយ មានកូន៣នាក់ ឪពុកឈ្មោះ [redacted] ស៊ិត(រស់) ម្តាយឈ្មោះ [redacted] មៀន (ស្លាប់) ប្រវត្តិនៃការផ្តន្ទាទោសដោយតុលាការ ធ្លាប់ជាប់ពន្ធនាគាររយៈពេល៦ខែ ពាក់ព័ន្ធនឹងការក្លែងធ្វើជាមន្ត្រីរាជការ **(ក្នុងឃុំ)**។

២-ជនជាប់ចោទឈ្មោះ [redacted] **សារិន** ភេទប្រុស អាយុ៦០ឆ្នាំ កើតនៅថ្ងៃទី៥ ខែកញ្ញា ឆ្នាំ១៩៦០ ជនជាតិខ្មែរ មុខរបរកសិករ កម្រិតវប្បធម៌ថ្នាក់ទី៧ចាស់ ទីកន្លែងកំណើត [redacted] ខេត្តកំពង់ធំ ទីលំនៅបច្ចុប្បន្ន [redacted] ខេត្តកំពង់ធំ ប្រពន្ធឈ្មោះ [redacted] ប៊ូតាន់ មានកូន៣នាក់ ឪពុកឈ្មោះ [redacted] ស៊ិន (ស្លាប់) ម្តាយឈ្មោះ [redacted] អ៊ឹម (រស់) ទោសពីមុនគ្មាន **(ក្រៅឃុំ)**។

៣-ជនជាប់ចោទឈ្មោះ [redacted] **សុគុណា** ភេទប្រុស អាយុ៣៨ឆ្នាំ កើតនៅថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៨២ ជនជាតិខ្មែរ សញ្ជាតិខ្មែរ ទីកន្លែងកំណើត [redacted] ខេត្តកំពង់ធំ ទីលំនៅបច្ចុប្បន្ននៅភូមិពាក់ស្នែងថ្មី ឃុំពាក់ស្នែង ស្រុកអង្គរធំ ខេត្តសៀមរាប កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ 180445358 (1) ចុះថ្ងៃទី៦ ខែមីនា ឆ្នាំ២០១៩ មុខរបរកសិករ ប្រពន្ធឈ្មោះ [redacted] **ចំរើន** មានកូន២នាក់ ឪពុកឈ្មោះ [redacted] **គង់** (ស្លាប់) ម្តាយឈ្មោះ [redacted] **ណូយ** (រស់) **(ក្រៅឃុំ)**។

៤-ជនជាប់ចោទឈ្មោះ [redacted] **សេរីមុន្នី** ហៅ **សេរីវឌ្ឍនៈ** ភេទប្រុស អាយុ២៥ឆ្នាំ កើតនៅឆ្នាំ១៩៩៦ ជនជាតិខ្មែរ សញ្ជាតិខ្មែរ ទីកន្លែងកំណើតនៅ [redacted] ខេត្តកំពង់ធំ ទីលំនៅបច្ចុប្បន្ន [redacted] ខេត្តកំពង់ធំ កម្រិតវប្បធម៌ថ្នាក់បរិញ្ញាបត្រ មុខរបរកស៊ី ឪពុកឈ្មោះ [redacted] **សារិន** (រស់) ម្តាយឈ្មោះ [redacted] **ប៊ូតាន់** (រស់) **(គេចខ្លួន)**។

៥-ជនជាប់ចោទឈ្មោះ [redacted] **ឈុនឡេង** ភេទប្រុស អាយុ៤៧ឆ្នាំ កើតនៅថ្ងៃទី១៥ ខែឧសភា ឆ្នាំ១៩៧៣ ជនជាតិខ្មែរ សញ្ជាតិខ្មែរ ទីកន្លែងកំណើតនៅ [redacted] ខេត្តកំពង់ធំ ទីលំនៅបច្ចុប្បន្ន [redacted] ខេត្តកំពង់ធំ មុខរបរមន្ត្រីរាជការ ប្រពន្ធឈ្មោះ [redacted] **ហ៊្សែ** មានកូន៣នាក់ ឪពុកឈ្មោះ [redacted] **ឡៃ** ម្តាយឈ្មោះ [redacted] **ស៊ឹម** (រស់) **(គេចខ្លួន)**។

៦-ជនជាប់ចោទឈ្មោះ [redacted] **សេរីរ័ត្ន** ភេទប្រុស អាយុ២៧ឆ្នាំ កើតនៅឆ្នាំ១៩៩៤ ជនជាតិខ្មែរ សញ្ជាតិខ្មែរ ទីកន្លែងកំណើតនៅ [redacted] ខេត្តកំពង់ធំ ទីលំនៅបច្ចុប្បន្ននៅភូមិ [redacted] ខេត្តកំពង់ធំ កម្រិតវប្បធម៌ថ្នាក់បរិញ្ញាបត្រ មុខរបរបុគ្គលិកក្រុមហ៊ុន ប្រពន្ធឈ្មោះ [redacted] **ស្រីរ័ត្ន** មានកូន១នាក់ ឪពុកឈ្មោះ [redacted] **សារិន** (រស់) ម្តាយឈ្មោះ [redacted] **ប៊ូតាន់** -រស់- **(គេចខ្លួន)**។

៧-ជនជាប់ចោទឈ្មោះ [redacted] **ឆៃគី** ភេទប្រុស អាយុ៣២ឆ្នាំ កើតនៅឆ្នាំ១៩៨៩ ជនជាតិខ្មែរ សញ្ជាតិខ្មែរ ទីកន្លែងកំណើតនៅ [redacted] ខេត្តកំពង់ធំ ទីលំនៅបច្ចុប្បន្ននៅភូមិពាក់ស្នែងថ្មី ឃុំពាក់ស្នែង ស្រុកអង្គរធំ ខេត្តសៀមរាប មុខរបរកសិករ ប្រពន្ធឈ្មោះ **នី** មានកូន១នាក់ ឪពុកឈ្មោះ [redacted] **គង់** -ស្លាប់- ម្តាយឈ្មោះ [redacted] **ណូយ** -រស់- **(គេចខ្លួន)**។



Scanned with CamScanner

៨-ជនជាប់ចោទឈ្មោះ [redacted] **អ៊ិច** ភេទប្រុស អាយុ៤៣ឆ្នាំ កើតនៅថ្ងៃទី៧ ខែសីហា ឆ្នាំ១៩៧៩ ជនជាតិខ្មែរ សញ្ជាតិខ្មែរ កាន់សាសនាព្រះពុទ្ធ មុខរបរយោធា អត្តលេខ ២១៨៣៣ ជាមេបញ្ជាការរងវរៈសេនាតូចលេខ៣ តំបន់ប្រតិបត្តិការសិករងកោះកុង យុទ្ធភូមិភាគ៣ ប្រើប្រាស់ទូរស័ព្ទលេខ 066 363 638 (គេចខ្លួន)។

ត្រូវបានដាក់ឲ្យស្ថិតនៅក្រោមការពិនិត្យពីបទ **ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោស** ពីបទ **ចាប់ដោយខុសច្បាប់** ពីបទ **គំរាមកំហែងថានឹងសម្លាប់ដោយមានបញ្ជាឱ្យបំពេញលក្ខខណ្ឌ** ពីបទ **ធ្វើឱ្យខូចខាតដោយចេតនា** និង ពីបទ **លុចបំបាត់វត្ថុតាង** ប្រព្រឹត្តនៅភូមិលៀប ឃុំពាក់ស្នែង ស្រុកអង្គរធំ ខេត្តសៀមរាប កាលពីថ្ងៃទី១៥ ខែមីនា ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌដែលមានចែងនិងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា**២១៨ មាត្រា២៥៣ ចំណុច១ មាត្រា២៣៤ មាត្រា៤១០ មាត្រា៤១១ និងមាត្រា៥៣៣** នៃក្រមព្រហ្មទណ្ឌ។

## ដំណើររឿងហេតុមានដូចតទៅ

កាលពីថ្ងៃទី១៥ ខែមីនា ឆ្នាំ២០២១ វេលាម៉ោង១៦ និង១០នាទី ដែលមានជនរងគ្រោះឈ្មោះ [redacted] សុវណ្ណ ឈ្មោះ [redacted] ចឿប ឈ្មោះ [redacted] សឿត និងឈ្មោះ [redacted] យ៉ាកំពុងតែឈរមើលត្រាក់ទ័រភ្ជួរដីចំការនៅចំណុចអូរជ្រៅ ស្ថិតនៅក្នុងភូមិលៀប ឃុំពាក់ស្នែង ស្រុកអង្គរធំ ខេត្តសៀមរាប ស្រាប់តែមានរថយន្តចំនួន២គ្រឿង ម៉ាក LUXUS LX 470 មិនស្គាល់សេរី(ពាក់ស្លាកលេខ ខ.ភ.ម) មិនចាំលេខ និងមួយគ្រឿងទៀត ពណ៌ខ្មៅ មិនស្គាល់ម៉ាកបានបើកមកឈប់នៅមុខដីចំការ ។ ពេលនោះជនសង្ស័យឈ្មោះ [redacted] សារិន បានចុះពីលើរថយន្ត ហើយបានស្រែកគំរាមមិនឱ្យភ្ជួរដីចំការទៀតទេ ។ លុះបានប្រហែល១៥នាទី ឈ្មោះ [redacted] សារិន ឈ្មោះ [redacted] ឆៃគី ឈ្មោះ [redacted] សុគុណ ឈ្មោះ ជាម ឈុនឡេង ឈ្មោះ [redacted] សេង ឈ្មោះ [redacted] សេរីវឌ្ឍនៈ និងឈ្មោះ [redacted] សេរីរត្ន បានចូលទៅចាប់ជនរងគ្រោះឈ្មោះ [redacted] សុវណ្ណ និងឈ្មោះ [redacted] ចឿប ដាក់ចូលក្នុងឡាន ចំណែកឯឈ្មោះ [redacted] សឿត និងឈ្មោះ [redacted] យ៉ា រត់គេចខ្លួនរួច ហើយជនសង្ស័យឈ្មោះ [redacted] សារិន ឈ្មោះ [redacted] សេរីវឌ្ឍនៈ និងឈ្មោះ [redacted] សេរីរត្ន បាននាំគ្នាដកយកទូរស័ព្ទដៃរបស់ជនរងគ្រោះចំនួន៤គ្រឿង លុយចំនួន ៤០០,០០០ (សែសិបម៉ឺន) រៀល និងវិទ្យុទាក់ទង (អាយគម) ចំនួន០១គ្រឿង និងបានជិះឡាននាំឈ្មោះ [redacted] សុវណ្ណ និងឈ្មោះ [redacted] ចឿប ទៅជួបឈ្មោះ [redacted] អ៊ិច នៅចំណុចស្រះឈូក ស្ថិតនៅក្នុងភូមិបន្ទាយស្រី ឃុំខ្នារសណ្ដាយ ស្រុកបន្ទាយស្រី ខេត្តសៀមរាប ហើយឈ្មោះ [redacted] អ៊ិច បានប្រាប់ទៅជនរងគ្រោះថា បើជនរងគ្រោះទៅជាន់ដីនឹងទៀតរូបគេនឹងសម្លាប់ជនរងគ្រោះទាំងគ្រួសារចោល ។ បន្ទាប់មកឈ្មោះ [redacted] អ៊ិច បានយកវិទ្យុទាក់ទង (អាយគម) ពោកទៅនឹងឈើបណ្ដាលឱ្យបែក មួយសន្ទុះក្រោយមកក្រុមរបស់ឈ្មោះ [redacted] អ៊ិច បានចេញទៅវិញអស់ ហើយឈ្មោះ [redacted] ចឿប និងឈ្មោះ [redacted] សុវណ្ណ បានដើរចេញមកថ្នល់ក៏ជួបឈ្មោះ [redacted] សំបូរ ក៏នាំទៅប្ដឹងសមត្ថកិច្ច ។ ហេតុដល់ថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០២១ កម្លាំងការិយាល័យព្រហ្មទណ្ឌបានចុះទៅកាន់ទីតាំងដី ស្ថិតនៅភូមិលៀប ឃុំពាក់ស្នែង ស្រុកបន្ទាយស្រី ខេត្តសៀមរាប បានអនុវត្តដីកាបញ្ជាឲ្យចូលខ្លួនលេខ ២១៣/២១ លេខ២១៤/២១ លេខ២១៥/២១ និងលេខ២១៩/២១ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០២១ របស់អយ្យការអមសាលាដំបូងខេត្តសៀមរាប បានឃាត់ខ្លួនជនសង្ស័យចំនួន៤នាក់ ឈ្មោះ [redacted] សារិន ឈ្មោះ [redacted] សេរីវឌ្ឍនៈ ឈ្មោះ [redacted] សេរីរត្ន និងឈ្មោះ [redacted] សុគុណ ។



Scanned with CamScanner

**បានឃើញ** ដីកាសម្រេចបញ្ជូលសំណុំរឿងលេខ ១១៨ រប/២៣ ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ ២០២៣ របស់ប្រធានសាលាដំបូងខេត្តសៀមរាប។

**បានឃើញ** ដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខ ៤៧៤៦ ពស.ព្រស/ជ ចុះថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០២១ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តសៀមរាប។

**បានឃើញ** ដីកាចាត់តាំងចៅក្រមជំនុំជម្រះលេខ ៩៧ ពស.ព្រជ (ក) ចុះថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ ២០២២ របស់ប្រធានសាលាដំបូងខេត្តសៀមរាប។

**<u>នាពេលសវនាការ</u>**

- ជនជាប់ចោទឈ្មោះ [redacted]សេង បានឆ្លើយថា នៅថ្ងៃទី០១ ខែឧសភា ឆ្នាំ២០២១ ខាងប៉ុស្តិ៍នគរបាលសង្កាត់សាលាកំរើក បានកោះហៅខ្ញុំបាទមកសួរនាំពាក់ព័ន្ធនឹងការចោទប្រកាន់ខ្ញុំបាទថា ខ្ញុំបាទបានលួចយកទូរស័ព្ទរបស់ឈ្មោះ [redacted] សុវណ្ណ ឈ្មោះ [redacted] ធឿប ឈ្មោះ [redacted] យ៉ា និងឈ្មោះ [redacted] សឿត និងបានឃាត់ខ្លួនខ្ញុំបាទនៅថ្ងៃនោះតែម្តង ។ ខ្ញុំបាទសូមបដិសេធថា ខ្ញុំបាទមិនបានយកទូរស័ព្ទដូចការចោទប្រកាន់នោះទេ ។ ខ្ញុំបាទស្គាល់ឈ្មោះ [redacted] សុវណ្ណ ឈ្មោះ [redacted] ធឿប ឈ្មោះ [redacted] យ៉ា និងឈ្មោះ [redacted] សឿត ដោយសារពួកគាត់ជាអ្នករស់នៅក្នុងឃុំតែមួយ តែភូមិខុសគ្នា ។ នៅថ្ងៃទី១៥ ខែមីនា ឆ្នាំ២០២១ នៅពេលដែលមានការទាស់ទែងគ្នានៅភូមិលៀប ឃុំពាក់ស្នែង ស្រុកអង្គរធំ ខេត្តសៀមរាប ខ្ញុំបាទមិនបាននៅទីនោះទេ គឺខ្ញុំបាទបានទៅចូលរួមសវនាការនៅសាលាឧទ្ធរណ៍ខេត្តបាត់ដំបងជាមួយលោកមេធាវី [redacted] ហើយចំពោះរាល់ឯកសារដីកាកោះហៅរបស់តុលាការគឺនៅលោក [redacted] ។ ទាល់តែរំលងបានពីរថ្ងៃក្រោយមក ទើបខ្ញុំបាទបានដឹងតាមរយៈមើលហ្វេសប៊ុកមានគេបង្ហោះថាប្រជាពលរដ្ឋមានទំនាស់ដីធ្លីនៅភូមិលៀប ឃុំពាក់ស្នែង ស្រុកអង្គរធំ ខេត្តសៀមរាប ។ ខ្ញុំបាទស្គាល់ឈ្មោះ [redacted] សារិន ជាអ្នកប្រមូលទិញដី ។ ឈ្មោះ [redacted] សុគុណ និងឈ្មោះ [redacted] ឆៃគី ជាអ្នកស្រុករស់ភូមិឃុំជាមួយខ្ញុំបាទ ។ ឈ្មោះ [redacted] សេរីវុឌ្ឍ និងឈ្មោះ [redacted] សេរីវត្ថ ខ្ញុំបាទមិនស្គាល់ទេ ។ ឈ្មោះ [redacted] ធឿប ឈ្មោះ [redacted] សុវណ្ណ ខ្ញុំស្គាល់ជាអ្នកចាំចំការឱ្យឈ្មោះ [redacted] សារិន ។ ឈ្មោះ [redacted] អ៊ុច ខ្ញុំបាទមិនស្គាល់ទេ ។ ខ្ញុំមិនដែលមានទំនាស់ជាមួយឈ្មោះ [redacted] ធឿប និងឈ្មោះ [redacted] សុវណ្ណ ទេ ពីព្រោះខ្ញុំគ្មានដីនៅទីតាំងនៅភូមិលៀបទេ ។ ខ្ញុំមិនដែលមានទំនាស់ជាមួយឈ្មោះ [redacted] សារិន ទេ ។ ខ្ញុំបាទសូមឆ្លើយបញ្ជាក់ម្តងទៀតថានៅថ្ងៃទី១៥ ខែមីនា ឆ្នាំ២០២១ ខ្ញុំបាទមានទំនាស់ជាមួយឈ្មោះ [redacted] ធឿប និងឈ្មោះ [redacted] សឿត ដោយខ្ញុំបាទបាននាំប្រជាជនចំនួន៤១នាក់ ក្នុងនោះមានឈ្មោះ [redacted]ស៊ុក ឈ្មោះ [redacted]ពិក និងឈ្មោះ [redacted]រឿត ទៅហាមឃាត់ឈ្មោះ [redacted] ធឿប និងឈ្មោះ [redacted] សឿត កុំឱ្យឈូសឆាយ និងភ្ជួរដីចំនួន២០០ហិកតាជាង ក្នុងនោះមានដីម្តាយខ្ញុំបាទចំនួន៤ហិកតាផងដែរ ខ្ញុំបាទមិនបានប្រើហិង្សា និងមិនបានចាប់ឃាត់ខ្លួនពួកគាត់ដាក់ចូលឡាននោះទេ ពីព្រោះខ្ញុំបាទគ្មានឡានជិះទេ ។ នៅថ្ងៃទី១៥ ខែមីនា ឆ្នាំ២០២១ គឺមិនមានឈ្មោះ [redacted] សារិន ឈ្មោះ [redacted] សេរីវុឌ្ឍ ឈ្មោះ [redacted] សេរីវត្ថ និងឈ្មោះ គង់ សុគុណ ចូលរួមទេ មានតែខ្ញុំបាទ និងប្រជាជន៤១នាក់ តែប៉ុណ្ណោះ ។ ហើយដីនោះមានចម្ងាយពីដីរបស់ឈ្មោះ [redacted] សារិន ប្រហែលជា១០គីឡូម៉ែត្រ ហើយដីនេះអាជ្ញាធរបានហាមឃាត់មិនអនុញ្ញាតឱ្យឈូសឆាយឡើយ ប៉ុន្តែឈ្មោះ [redacted] ធឿប និងឈ្មោះ [redacted] សឿត នៅតែបំពានមានការឈូសឆាយ ទើបខ្ញុំបាទនាំប្រជាជនទាំង៤១នាក់ ដើម្បីទៅសួរនាំរកឯកសារតែប៉ុណ្ណោះ។ ខ្ញុំបាទស្គាល់ឈ្មោះ [redacted] សារិន គាត់ជាអ្នកដើរទិញដី ។ ខ្ញុំស្គាល់ឈ្មោះ [redacted] ឈុនឡេង ។



Scanned with CamScanner

- ជនជាប់ចោទឈ្មោះ [redacted] សារិន បានឆ្លើយថា នៅថ្ងៃទី១៥ ខែមីនា ឆ្នាំ២០២១ គឺខ្ញុំបាទបានទៅហូបការនៅអូរម្នាស់ ហូបការនៅម៉ោង១១ ចេញមកវិញនៅម៉ោង២រសៀល ខ្ញុំបាទចេញទៅស្រុកស្ទួង ខេត្តកំពង់ធំវិញ ។ ខ្ញុំបាទទៅហូបការជាមួយកូនខ្ញុំបាទឈ្មោះ [redacted] សេរីវុឌ្ឍ និងឈ្មោះ [redacted] សេរីរ័ត្ន ។ ចំពោះឈ្មោះ [redacted] ឈុនឡេង គាត់មកហូបដែរ ប៉ុន្តែជិះមកផ្សេងគ្នា ។ ពេលចេញពីកន្លែងហូបការខ្ញុំបាទបានជិះម៉ូតូម្នាក់ឯង ទៅផ្ទះមុនគេនៅស្រុកស្ទួង ខេត្តកំពង់ធំ ។ ខ្ញុំអត់មានឡានទេ ។ ចំណែកកូនខ្ញុំបាទនៅហូបការបន្ត ដោយពេលទៅផ្ទះវិញគាត់ជិះឡានជាមួយអ្នកដទៃ ខ្ញុំអត់ដឹងថាឡានម៉ាកអីនោះទេ ហើយមិនដឹងថាជិះទៅជាមួយអ្នកណាដែរ ។ ចំពោះឈ្មោះ [redacted] ឈុនឡេង ខ្ញុំមិនដឹងថាគាត់ជិះឡានម៉ាកអីនោះទេ ។ ខ្ញុំស្គាល់ស្រះឈូកធ្លាប់ជិះឆ្លងកាត់កន្លងមក ។ ខ្ញុំមិនស្គាល់ឈ្មោះ [redacted] អ៊ិច ទេ ធ្លាប់ឮតែឈ្មោះ ។ ខ្ញុំបាទមិនបានចាប់ឈ្មោះ [redacted] សុវណ្ណ និងឈ្មោះ [redacted] បឿប ដាក់ចូលក្នុងឡានដឹកយកទៅឱ្យឈ្មោះ [redacted] អ៊ិច នៅស្រះឈូកនោះទេ ។ ចំពោះដីមួយកន្លែងស្ថិតនៅភូមិលៀប ឃុំពាក់ស្នែង ស្រុកអង្គរធំ ខេត្តសៀមរាប មូលហេតុដែលខ្ញុំបាទតែងទៅទីតាំងដីខាងលើនោះ ដោយសារដីខាងលើគឺជាដីដែលខ្ញុំបាទបានទិញ និងមានការប្តឹងផ្តល់គ្នាវែងឆ្ងាយចាប់ពីសាលាដំបូងខេត្ត រហូតដល់តុលាការកំពូល ។ ចំពោះដីរបស់ក្រុម [redacted] សេងមានចម្ងាយពីដីខ្ញុំប្រហែលជា២គីឡូម៉ែត្រ មិនមែននៅក្បែរដីខ្ញុំទេ ។ ហើយថ្ងៃដែលឈ្មោះ [redacted] សេង មានទំនាស់ជាមួយក្រុម [redacted] សារិន គឺខ្ញុំនៅកន្លែងហូបការនៅអូរម្នាស់ ខ្ញុំមិនបានដឹងពីការកើតហេតុរវាងក្រុម [redacted] សេង និងក្រុម [redacted] សារិន នោះទេ ពីព្រោះដីរបស់ខ្ញុំបាទមានទីតាំងផ្សេងពីគ្នា ។

- ជនជាប់ចោទឈ្មោះ [redacted] ឈុនឡេង បានឆ្លើយថា នៅថ្ងៃទី១៥ ខែមីនា ឆ្នាំ២០២១ ខ្ញុំបាទបានទៅហូបការកូនពូធាតនៅអូរម្នាស់ ពេលទៅដល់កន្លែងការខ្ញុំឃើញមានភ្ញៀវចាប់ផ្តើមចេញមកផ្ទះវិញបណ្តើរៗ។ ខ្ញុំហូបការរហូតដល់ល្ងាចក៏ចេញមកផ្ទះវិញ ដោយមានគេសុំជិះឡានខ្ញុំបាទទៅជាមួយផងដែរ ។ ខ្ញុំបាទមិនចាំថាអ្នកដែលសុំខ្ញុំជិះទៅជាមួយមានប៉ុន្មាននាក់នោះទេ ។ ក្នុងនោះក៏មានឈ្មោះ [redacted] សេរីវុឌ្ឍ និងឈ្មោះ [redacted] សេរីរ័ត្ន ផងដែរ ។ ខ្ញុំមិនដឹងថាឈ្មោះ [redacted] សារិន គាត់ជិះអ្វីនោះទេ ។ ខ្ញុំបាទមិនមានទំនាស់ជាមួយឈ្មោះ [redacted] សុវណ្ណ និងឈ្មោះ [redacted] បឿប នោះទេ ពីព្រោះខ្ញុំបាទមិនមានដីនៅទីនោះទេ ខ្ញុំទៅតតាំងអីជាមួយប្រជាជន ប៉ុន្តែកន្លងមកឈ្មោះ [redacted] សារិន ធ្លាប់នាំខ្ញុំទៅរកទិញដីនៅទីនោះផងដែរ ពីព្រោះឈ្មោះ [redacted] សារិន ជាអ្នករស់ស្រុកស្ទួង ខេត្តកំពង់ធំ ជាមួយខ្ញុំគាត់មានដីនៅទីនោះ ក៏នាំខ្ញុំទៅមើលជាមួយគាត់ ។ ខ្ញុំមិនស្គាល់ឈ្មោះ [redacted] អ៊ិច ច្បាស់ទេ ពីព្រោះគាត់ធ្វើការងារផ្សេង ខ្ញុំធ្វើការងាររបស់ខ្ញុំផ្សេងដែរ ។

- ជនជាប់ចោទឈ្មោះ [redacted] សេរីវុឌ្ឍ បានឆ្លើយថា នៅថ្ងៃទី១៥ ខែមីនា ឆ្នាំ២០២១ ខ្ញុំបាទបានទៅហូបការជាមួយនឹងឈ្មោះ [redacted] សេរីរ័ត្ន និងប៉ាខ្ញុំឈ្មោះ [redacted] សារិន នៅអូរម្នាស់ នៅពេលហូបការរួច ខ្ញុំបាទបានសុំឡានឈ្មោះ [redacted] ឈុនឡេង ជិះមកជាមួយផងដែរ ។ ខ្ញុំបាទមិនស្គាល់ទីតាំងដែលមានទំនាស់រឿងដីធ្លីនោះទេ ពីព្រោះខ្ញុំបាទរស់នៅស្រុកស្ទួង ខេត្តកំពង់ធំ ។

- ជនជាប់ចោទឈ្មោះ [redacted] សេរីរ័ត្ន បានឆ្លើយថា នៅថ្ងៃទី១៥ ខែមីនា ឆ្នាំ២០២១ ខ្ញុំបាទបានទៅហូបការជាមួយនឹងឈ្មោះ [redacted] សេរីវុឌ្ឍ និងប៉ាខ្ញុំឈ្មោះ [redacted] សារិន នៅអូរម្នាស់ នៅពេលហូបការរួច ខ្ញុំបាទបានសុំឡានឈ្មោះ [redacted] ឈុនឡេង ជិះមកជាមួយផងដែរ ។ ខ្ញុំបាទមិនស្គាល់ទីតាំងដែលមានទំនាស់នោះទេ ពីព្រោះខ្ញុំបាទរស់នៅស្រុកស្ទួង ខេត្តកំពង់ធំ ។

- ចម្លើយជនត្រូវចោទឈ្មោះ [redacted] សុគុណ បានឆ្លើយថា នៅថ្ងៃទី១៥ ខែមីនា ឆ្នាំ២០២១ គឺខ្លួនបាននៅផ្ទះ ស្ថិតនៅភូមិពាក់ស្នែងថ្មី ឃុំពាក់ស្នែង ស្រុកអង្គរធំ ខេត្តសៀមរាប ដោយពុំបានចេញពីផ្ទះទៅ



Scanned with CamScanner

ណានោះទេ ដោយខ្លួននៅផ្ទះជួសជុលម៉ូតូ ដោយខ្លួនជាជាងជួលជុលម៉ូតូ ។ ខ្លួនធ្លាប់ឮឈ្មោះ [redacted] សុវណ្ណ ប៉ុន្តែខ្លួនមិនស្គាល់មុខមាត់គាត់ទេ ។ ខ្លួនស្គាល់ឈ្មោះ [redacted] ជឿប និងឈ្មោះ [redacted] សឿត ខ្លួនស្គាល់ពួកគាត់ទាំងពីរនេះ ដោយគាត់ជាអ្នកភូមិរស់នៅជាមួយខ្លួន ។ ឈ្មោះ [redacted] យ៉ា ខ្លួនមិនស្គាល់គាត់ទេ។ ខ្លួនស្គាល់ឈ្មោះ [redacted] សារីន ប៉ុន្តែមិនជិតស្និទ្ធិជាមួយនឹងគ្នានោះទេ។ ខ្លួនស្គាល់ឈ្មោះ [redacted] សារីន ដោយសារគាត់មានដីនៅក្បែរដីរបស់ឈ្មោះ [redacted]ារិន ស្ថិតនៅភូមិលៀប ឃុំពាក់ស្នែង ស្រុកអង្គរធំ ខេត្តសៀមរាប ដោយធ្លាប់មានវិវាទរឿងដីធ្លីជាមួយនឹងឈ្មោះ [redacted] សារិន ប៉ុន្តែមិនដែលមានការឈ្លោះជាមួយនឹងគ្នានោះទេ។ ខ្ញុំមិនស្គាល់ឈ្មោះ [redacted] ឈុនឡេង នោះទេ ។ ចំពោះឈ្មោះ [redacted] សេរីវុឌ្ឍ និងឈ្មោះ [redacted] សេរីរ័ត្ន ខ្ញុំស្គាល់ត្រូវជាក្មួយរបស់ខ្ញុំ ។ ខ្ញុំស្គាល់ឈ្មោះ [redacted] ឆៃគី ត្រូវជាប្អូនបង្កើតខ្ញុំបាទ ។ ឈ្មោះ [redacted] អ៊ុច មិនស្គាល់ ។ ខ្ញុំស្គាល់ឈ្មោះ [redacted] សេង ។ នៅថ្ងៃទី១៥ ខែមីនា ឆ្នាំ២០២១ ខ្លួនមិនដឹងអ្នកណាចាប់ឈ្មោះ [redacted] សឿត ឈ្មោះ សោម សុវណ្ណ ចូលឡាននោះទេ។

- ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] **សុវណ្ណ** បានឆ្លើយថា កាលពីថ្ងៃទី១៥ ខែមីនា ឆ្នាំ២០២១ នៅវេលាម៉ោង៩ និង៣០នាទី ព្រឹក មានខ្លួន មានឈ្មោះ [redacted] ជឿប និងឈ្មោះ [redacted] សឿត បានជិះម៉ូតូចំនួន ៣គ្រឿង ធ្វើដំណើរចេញពីផ្ទះរបស់ពួកខ្លួនក្នុងភូមិលៀប ឃុំពាក់ស្នែង ស្រុកអង្គរធំ ខេត្តសៀមរាប ទៅមើលត្រាក់ទ័រភ្ជួរដីចំការដំឡូងមីឱ្យឈ្មោះ [redacted] សារីន ដែលមានទីតាំងស្ថិតនៅចំណុចអូរកន្សែង ក្នុងភូមិលៀប ឃុំពាក់ស្នែង ស្រុកអង្គរធំ ខេត្តសៀមរាប ។ នៅពេលដែលពួកខ្លួនទាំង៣នាក់ខាងលើ ទៅដល់ចំការដំឡូងមីនោះ នៅវេលាម៉ោង៤ និង៣០នាទីល្ងាច ទើបឈ្មោះ [redacted] យ៉ា បានដល់ដែល ស្រាប់តែមានមនុស្សមួយក្រុមមានគ្នាប្រហែល៨នាក់ ឈ្មោះ [redacted] សារិន ឈ្មោះ [redacted] សេរីរ័ត្ន ឈ្មោះ [redacted] សេរីវុឌ្ឍ ឈ្មោះ [redacted] ឈុនឡេង ឈ្មោះ [redacted] សុគុណ ឈ្មោះ [redacted] ឆៃគី ឈ្មោះ [redacted] សេង និងបក្ខពួកមួយចំនួនទៀត ជិះរថយន្តចំនួន២គ្រឿង ម៉ាកជុនដ្រា ពណ៌ប្រផេះ ពាក់ស្លាកលេខ **កំពង់ធំ 2B -1116** និងរថយន្ត១គ្រឿងទៀត ពុំស្គាល់ម៉ាក ពណ៌ខ្មៅ ពាក់ស្លាកលេខ **ខម (មិនចាំស្លាកលេខ)** ហើយមនុស្សទាំង៨នាក់នោះ បានមកហ៊ុំព័ទ្ធពួកខ្លួនទាំងបួននាក់ នៅក្នុងចំការដំឡូងមីខាងលើនេះ ដោយពេលនោះគឺពួកគេបានចាប់ខ្ញុំបាទ និងឈ្មោះ [redacted] ជឿប និងបានវាយ ទាត់ជាក់ ចាប់ព័ទ្ធស្លាបសេក (ព័ទ្ធដៃទៅក្រោយ) ដកយកទូរស័ព្ទចំនួន៤គ្រឿង និងវិទ្យុទាក់ទង (អាយគម) ចំនួន១គ្រឿង រួចអូសខ្លួន និងឈ្មោះ [redacted] ជឿប ដាក់ចូលក្នុងរថយន្តយកទៅជួបបក្ខពួកគេនៅចំណុចស្រះឈូក ស្ថិតនៅភូមិបន្ទាយស្រី ឃុំខ្នារសណ្ដាយ ស្រុកបន្ទាយស្រី ខេត្តសៀមរាប ដោយមានបក្ខពួករបស់ពួកគេឈ្មោះ [redacted] អ៊ុច និងអ្នកដទៃមិនស្គាល់ឈ្មោះនៅទីនោះផងដែរ។ ពេលនោះឈ្មោះ [redacted] អ៊ុច បាននិយាយគំរាមថា បើសិនពួកខ្ញុំបាទទៅជាន់ដីនៅកន្លែងចំការដំឡូងមីខាងលើនេះទៀត ពួកគេមិនត្រឹមតែមិនសម្លាប់ខ្ញុំបាទទេ គឺសម្លាប់ទាំងគ្រួសារតែម្តង ។ បន្ទាប់មកឈ្មោះ [redacted] អ៊ុច បានយកវិទ្យុទាក់ទង (អាយគម) បោកទៅនឹងឈើបណ្តាលឱ្យបែកអស់គ្មានសល់ ។ បន្ទាប់មកពួកគេទាំង៨នាក់ខាងលើព្រមទាំងបក្ខពួករបស់គេផ្សេងទៀត បាននាំគ្នាជិះឡានចេញអស់ទៅ ហើយខ្ញុំបាទនឹងឈ្មោះ [redacted] ជឿប បាននាំគ្នាដើរទៅកន្លែងសហគមន៍មួយយកន្លែងដើម្បីសុំប្រេងកូឡាលាប និងសុំទូរស័ព្ទដើម្បីទាក់ទងប្រាប់ទៅអ្នកផ្ទះ និងឈ្មោះ [redacted] សារីន ឱ្យពួកគាត់មកយកពួកខ្ញុំបាទ ។ ក្នុងនាមខ្លួនជាជនរងគ្រោះ និងជាដើមបណ្តឹងរដ្ឋប្បវេណីសូមសំណូមពរទៅតុលាការ ជួយរកយុត្តិធម៌ដល់ខ្លួនផង និងសូមទាមទារសំណងព្យាបាល និងសំណងជំងឺចិត្តសរុបចំនួន ៨០,០០០,០០០ (ប៉ែតសិបលាន) និងផ្តន្ទាទោសតាមច្បាប់ ។



Scanned with CamScanner

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ជឿប បានឆ្លើយថាកាលពីថ្ងៃទី១៥ ខែមីនា ឆ្នាំ២០២១ នៅវេលាម៉ោង៨ និង៣០នាទីព្រឹក ខ្លួនមានគ្នាចំនួន៣នាក់ គឺមានខ្ញុំបាទ មានឈ្មោះ [redacted] សឿត និងឈ្មោះ [redacted] សុវណ្ណ បានជិះម៉ូតូចំនួន៣គ្រឿង បានធ្វើដំណើរចេញពីផ្ទះរបស់ពួកខ្លួន ក្នុងភូមិលៀប និងភូមិពាក់ស្នែងថ្មី ឃុំពាក់ស្នែង ស្រុកអង្គរធំ ខេត្តសៀមរាប ទៅមើលត្រាក់ទ័រភ្ជួរដីចំការដំឡូងមីឱ្យឈ្មោះ [redacted] សារីន ដែលមានទីតាំងស្ថិតនៅចំណុចអូរកន្សែង ក្នុងភូមិលៀប ឃុំពាក់ស្នែង ស្រុកអង្គរធំ ខេត្តសៀមរាប នៅពេលដែលខ្ញុំបាទ មានឈ្មោះ [redacted] សឿត និងឈ្មោះ [redacted] សុវណ្ណ ទៅដល់ចំណុចដីចំការដំឡូងមីនោះនៅវេលាម៉ោង៩ និង១០នាទីព្រឹក ក៏នាំគ្នាមើលត្រាក់ទ័រភ្ជួរដី រហូតដល់វេលាម៉ោង៣ និង៤០នា ទី ល្ងាច ឈ្មោះ [redacted] សុវណ្ណ គាត់បានឱ្យខ្លួនទៅជួយមើលត្រាក់ទ័រភ្ជួរដីរបស់គាត់មួយកន្លែងទៀត ខ្លួនក៏បានទៅ ហើយខ្លួនក៏បានតេទូរស័ព្ទទៅឈ្មោះ [redacted] យ៉ា ឱ្យមកកន្លែងភ្ជួរដីនោះ ស្រាប់តែមានមនុស្សមួយក្រុមមានគ្នាប្រហែល៣នាក់ ជិះរថយន្តចំនួនមួយគ្រឿង មានឈ្មោះ [redacted] សេរីរ័ត្ន ឈ្មោះ [redacted] សេរីវុឌ្ឍ និងឈ្មោះ [redacted] ផៃគី បានជិះរថយន្តមកកន្លែងដីដែលកំពុងភ្ជួរនោះ ហើយបានគំរាមថានឹងសម្លាប់ និងបានជេរប្រមាថមកលើខ្លួន និងឈ្មោះ [redacted] សឿត ពេលនោះខ្លួនពុំបានតបតវិញនោះទេ។ បានមួយសន្ទុះក្រោយមកឈ្មោះ [redacted] យ៉ា បានមកដល់កន្លែងភ្ជួរដីរនោះ ក៏ស្រាប់តែមានរថយន្តមួយគ្រឿងមិនស្គាល់ម៉ាក មានគ្នាប្រាំនាក់ បានជិះមកតាមពីក្រោយឈ្មោះ [redacted] យ៉ា រហូតដល់កន្លែងភ្ជួរដីនោះ ពេលនោះមានឈ្មោះ [redacted] សារិន ឈ្មោះ [redacted] ឈុនឡេង ឈ្មោះ [redacted] សុគុណ និងឈ្មោះ [redacted] សេង ដោយពេលនោះដែរឈ្មោះ [redacted] សារិន និងឈ្មោះ [redacted] ឈុនឡេង បានស្រែកបញ្ជាឱ្យចាប់ឈ្មោះ [redacted] សុវណ្ណ ឈ្មោះ [redacted] ជឿប និងខ្ញុំបាទ ពេលអ្នកទាំង៨នាក់ខាងលើបានហ៊ុំព័ទ្ធពួកខ្លួនទាំងបួននាក់ ហើយដកហូតយកទូរស័ព្ទម៉ាកOPPO S9 ពណ៌ក្រហមចំនួនមួយគ្រឿង ប្រាក់ចំនួន ៤០០,០០០ (បួនសែន) រៀល និងវិទ្យុទាក់ទង (អាយគម) ចំនួនមួយគ្រឿងជារបស់ខ្លួន និងដកហូតទូរស័ព្ទដៃពីឈ្មោះ [redacted] យ៉ា ឈ្មោះ [redacted] សឿត និង ឈ្មោះ [redacted] សុវណ្ណ ចំនួន៣គ្រឿងទៀត បន្ទាប់មកពួកគេទាំង៨នាក់ខាងលើ បានចាប់ខ្ញុំបាទ និងឈ្មោះ [redacted] សុវណ្ណ ចាប់ដៃព័ទ្ធស្លាបសេកទៅក្រោយ ដាក់ចូលក្នុងរថយន្តរបស់ពួកគេ យកទៅជួបឈ្មោះ [redacted] អ៊ុច និងបក្ខពួកនៅចំណុចស្រះឈូក ស្ថិតនៅភូមិបន្ទាយស្រី ឃុំខ្នារសណ្តាយ ស្រុកបន្ទាយស្រី ខេត្តសៀមរាប នៅពេលដែលពួកគេបានយកខ្ញុំបាទ និងឈ្មោះ [redacted] សុវណ្ណ ទៅដល់ទីនោះ ឈ្មោះ [redacted] អ៊ុច បាននិយាយគំរាមថា បើសិនពួកខ្លួនទៅជាន់ដីនៅកន្លែងចំកាដំឡូងមីខាងលើនេះទៀត និងសម្លាប់ពួកខ្ញុំព្រមទាំងក្រុមគ្រួសារចោលទាំងអស់ បន្ទាប់មកឈ្មោះ [redacted] អ៊ុច បានយកវិទ្យុទាក់ទង (អាយគម) បោកទៅនឹងឈើបណ្តាលឱ្យបែក ហើយអ្នកទាំង៨នាក់ខាងលើ ព្រមទាំងបក្ខពួករបស់គេផ្សេងទៀត បានរត់គេចខ្លួនបាត់អស់ទៅ ។ សូមឱ្យតុលាការជួយរកយុត្តិធម៌ដល់ខ្លួន ខ្លួនសូមទាមទារសំណងខូចខាត និងសំណងជំងឺចិត្តសរុបចំនួន ២០,០០០ (ពីរម៉ឺន) ដុល្លារអាមេរិក និងផ្តន្ទាទោសតាមច្បាប់ ។

- ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] សឿត បានឆ្លើយថា ខ្ញុំបាទនិងឈ្មោះ [redacted] សុវណ្ណ ជាអ្នកមើលដីឱ្យឈ្មោះ [redacted] សារីន អស់រយៈពេល៧ឆ្នាំមកហើយ មិនមានអ្នកណាមករករឿងទេ គឺទើបតែនៅក្នុងអំឡុងឆ្នាំ២០២១ មានគេមករករឿងរហូត ដឹកនាំដោយឈ្មោះ [redacted] សេង ។ នៅថ្ងៃទី១៥ ខែមីនា ឆ្នាំ២០២១ ពួកគេបាននាំគ្នាមកប្រហែល៨ទៅ៩នាក់ ក្នុងនោះមានឈ្មោះ [redacted] សេង ឈ្មោះ [redacted] សារិន ឈ្មោះ [redacted] សេរីរ័ត្ន និងឈ្មោះ [redacted] សេរីវុឌ្ឍ ចំណែក៦នាក់ទៀតខ្លួនមិនស្គាល់ឈ្មោះទេ ដោយពួកគេបានមកបញ្ឈប់សកម្មភាពភ្ជួរដី ពេលនោះខ្លួនមានគ្នាចំនួនបីនាក់ ក្នុងនោះមានខ្ញុំបាទ មានឈ្មោះ [redacted] សុវណ្ណ



Scanned with CamScanner

និងឈ្មោះ [redacted] ជឿប ។ ដោយសារតែពួកខ្ញុំបាទមិនព្រមបញ្ឈប់សកម្មភាពក្បួរជើ ក្រុមរបស់ឈ្មោះ [redacted] សេង បាននាំគ្នាចូលមកចាប់ តែពេលនោះគេមិនបានចាប់ខ្លួនទេពីព្រោះខ្លួនបានរត់គេចទាន់ គឺចាប់បានតែឈ្មោះ [redacted] សុវណ្ណ និងឈ្មោះ [redacted] ជឿប តែប៉ុណ្ណោះ ។ ដោយពួកគេបានចាប់ដាក់ឡានយកទៅបាត់ ។ នៅថ្ងៃកើតហេតុនោះ ខ្ញុំបាទបានបាត់ទូរស័ព្ទចំនួន១គ្រឿង ទូរស័ព្ទរបស់ឈ្មោះ [redacted] ជឿប ចំនួន១គ្រឿង ទូរស័ព្ទរបស់ឈ្មោះ [redacted] សុវណ្ណ មួយគ្រឿង និងទូរស័ព្ទឈ្មោះ [redacted] យ៉ា ចំនួនមួយគ្រឿង ។ ចំពោះទូរស័ព្ទរបស់ខ្ញុំបាទគឺឈ្មោះ [redacted] សារិន ជាអ្នកលួចយកចេញពីហោប៉ៅខោរបស់ឈ្មោះ [redacted] ជឿប ដែលនៅក្នុងហោប៉ៅខោរបស់ឈ្មោះ [redacted] ជឿប មានទូរស័ព្ទចំនួន២គ្រឿង មួយគ្រឿងជារបស់ខ្ញុំបាទ និងមួយគ្រឿងជារបស់ឈ្មោះ [redacted] ជឿប ។ ពេលនោះទូស័ព្ទរបស់ឈ្មោះ [redacted] ជឿប អស់ថ្មហើយបានខ្ចីទូរស័ព្ទខ្ញុំបាទ ។ ខ្លួនសូមសំណូមពរទៅតុលាការជួយរកយុត្តិធម៌ដល់ខ្លួន ខ្លួនសូមទាមទារសំណងជំងឺចិត្ត ៤០,០០០,០០០ (សែសិបលាន)រៀល និងផ្តន្ទាទោសជនល្មើសតាមច្បាប់ ។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] យ៉ា បានឆ្លើយថា ខ្ញុំបាទបានស្គាល់ឈ្មោះ [redacted] សុវណ្ណ កាលពីអំឡុងឆ្នាំ២០១៣ ដោយសារតែខ្លួនបានទិញដីធ្វើចម្ការនៅជិតដីរបស់គាត់ ។ នៅថ្ងៃទី១៥ ខែមីនា ឆ្នាំ២០២១ វេលាម៉ោង៤ និង៣០ល្ងាច ឈ្មោះ [redacted] ជឿប បានតេទូរស័ព្ទហៅខ្លួនឱ្យទៅមើលត្រាក់ទ័រនៅចម្ការជំឡូងមី ពីព្រោះខ្លួនទើបតែទិញត្រាក់ទ័រថ្មីមិនទាន់ចេះបើក ។ ភ្លាមនោះខ្លួនក៏បានជិះម៉ូតូទៅចំការនោះ ពេលទៅដល់ក៏ស្រាប់តែឃើញឈ្មោះ [redacted] សុវណ្ណ និងឈ្មោះ [redacted] ជឿប កំពុងតែឈ្លោះប្រកែកគ្នាជាមួយមនុស្សមួយក្រុមដែលមានគ្នាប្រហែល៦ ទៅ៧នាក់ ក្នុងនោះខ្លួនស្គាល់៣នាក់ គឺឈ្មោះ [redacted] សេង ឈ្មោះ [redacted] សារិន និងឈ្មោះ [redacted] សេរីវុឌ្ឍ ក្រៅពីនេះខ្លួនមិនស្គាល់ទេ ។ ពេលកំពុងកើតហេតុ ខ្លួនមិនបានចូលទៅជួយខាងណានោះទេ គ្រាន់តែឈរមើលគេតែប៉ុណ្ណោះ ។ ហើយបានឃើញឈ្មោះ [redacted] សេរីវុឌ្ឍ តេទូរស័ព្ទហៅឪពុករបស់គេឈ្មោះ [redacted] សារិន ឱ្យមក បានមួយសន្ទុះក្រោយមកក៏ស្រាប់តែឃើញឈ្មោះអ៊ិន សារិន និងមនុស្សប្រុសម្នាក់ទៀតខ្លួនមិនស្គាល់ឈ្មោះទេ បានមកដល់ ហើយឈ្មោះ [redacted] សារិន ក៏បានបញ្ជាឱ្យអ្នកទាំង៦ ទៅ៧នាក់នោះ ចាប់ឈ្មោះ [redacted] សុវណ្ណ និងឈ្មោះ [redacted] ជឿប ដោយខ្លួនឮគេនិយាយថាចាប់ពួកគាត់យកទៅដាក់ក្នុងគុកនៅភ្នំពេញ ។ ពេលកំពុងតែមានការប្រវ៉ាយប្រតប់គ្នានោះ ឈ្មោះ [redacted] សុវណ្ណ បានឱ្យខ្លួនថតវីដេអូរាល់សកម្មភាពទាំងនោះដែរ តែខ្លួនមិនបានថតព្រោះពេលនោះខ្លួនកំពុងតែនិយាយទូរស័ព្ទជាមួយនឹងម៉ូយទិញផ្លែចន្ទី ។ ចំពោះអ្នកដែលចាប់ឈ្មោះ [redacted] សុវណ្ណ គឺឈ្មោះ [redacted] សារិន និងឈ្មោះ [redacted] សេរីរ័ត្ន ចំណែកអ្នកដែលចាប់ឈ្មោះ [redacted] ជឿប គឺខ្លួនមិនស្គាល់ឈ្មោះនោះទេ ។ ក្រោយពេលដែលពួកគេចាប់ឈ្មោះ [redacted] សុវណ្ណ និងឈ្មោះ [redacted] ជឿប រួច ឈ្មោះ [redacted] សារិន បានដើរមកសួរខ្លួនថា បានថត ឬអត់? ខ្លួនក៏បានប្រាប់គាត់ថាមិនបានថតទេ រួចគេក៏សុំឆែកទូរស័ព្ទដៃរបស់ខ្លួន ក៏មិនឃើញវីដេអូនោះដែរ ឈ្មោះ [redacted] សារិន នៅតែដកយកទូរស័ព្ទដៃរបស់ខ្លួន ហើយគេបាននិយាយថាចាំទៅយកនៅខាងមុខ ប៉ុន្តែរហូតមកដល់បច្ចុប្បន្ននេះ គេមិនបានឱ្យទូរស័ព្ទដៃនោះមកខ្លួនវិញទេ ។ មិនតែប៉ុណ្ណោះគេក៏បានបញ្ជាឱ្យបក្ខពួករបស់គេចាប់ខ្លួន និងឈ្មោះ [redacted] សៀត ដែលនៅទីនោះទៀតផង។ ពួកគេចាប់ខ្លួនមិនបាននោះទេ ព្រោះខ្លួន និងឈ្មោះ [redacted] សៀត បានរត់ទៅកន្លែងដែលមានមនុស្សច្រើន ទើបពួកគេមិនហ៊ានដេញតាម ។ ខ្លួនសូមសំណូមពរទៅតុលាការរកយុត្តិធម៌ដល់ខ្លួន ខ្លួនសូមទាមទារសំណងជំងឺចិត្ត ៥០០ (ប្រាំរយ) ដុល្លារអាមេរិក និងផ្តន្ទាទោសជនល្មើសតាមច្បាប់។

-សាក្សីឈ្មោះ [redacted] សារីន បានឆ្លើយថា ខ្ញុំបាទមានដីមួយផ្នែក និងដីមួយផ្នែកទៀតខ្ញុំបាទមើលថែឱ្យខាងក្រុមហ៊ុន ដោយខ្ញុំបាទមានអ្នកជួយមើលដីមានឈ្មោះ [redacted] សុវណ្ណ ឈ្មោះ [redacted] ជឿប និងឈ្មោះ [redacted] សឿត។ រៀងរាល់ខែមីនា ប្រជាពលរដ្ឋតែងតែមកជួលដីដើម្បីដាំដំឡូង ទើបខ្ញុំបានឱ្យឈ្មោះ សោម សុវណ្ណ ឈ្មោះ [redacted] ជឿប និងឈ្មោះ [redacted] សឿត ទៅមើលដីជាប្រចាំ។ ចំពោះដីដែលមានវិវាទគឺជាដីរបស់ក្រុមហ៊ុន ស្ថិតនៅភូមិលៀប ឃុំពាក់ស្នែង ស្រុកអង្គរធំ ខេត្តសៀមរាប នៅថ្ងៃទី១៥ ខែមីនា ឆ្នាំ២០២១ វេលាម៉ោង៩ព្រឹក ឈ្មោះ [redacted] សឿត បានតេទូរស័ព្ទប្រាប់ខ្ញុំថាក្រុមឈ្មោះ [redacted] សារិន ឈ្មោះ [redacted] អ៊ុច បានមករាំង និងហាមឃាត់មិនឱ្យភ្ជួរដី ពេលនោះខ្ញុំបានឱ្យឈ្មោះ [redacted] សំបូរ ទៅមើលព្រោះឈ្មោះ [redacted] សំបូរ កំពុងនៅជាមួយខ្ញុំ បន្ទាប់មកឈ្មោះ [redacted] សំបូរ ក៏បានទៅទីនោះ លុះដល់ម៉ោង១២ និង២០នាទី ឈ្មោះ [redacted] សំបូរ បានតេទូរស័ព្ទប្រាប់ខ្ញុំថាកំពុងតែតានតឹងខ្លាំង ។ មួយសន្ទុះក្រោយមកបានតេទូរស័ព្ទមកខ្ញុំម្តងទៀតថា អត់អីទេ ពួកវាទៅអស់ហើយ ។ ហើយឈ្មោះ [redacted] សំបូរ បានជិះឡានមកទីរួមខេត្តសៀមរាបវិញ ។ លុះដល់ម៉ោងប្រហែលជា៤ល្ងាចជាង ឈ្មោះ [redacted] សឿត បានតេទូរស័ព្ទប្រាប់ខ្ញុំថាឥលូវនេះក្រុមឈ្មោះ [redacted] អ៊ុច ឈ្មោះ [redacted] សារិន ចូលមកម្តងទៀត បានវាយមកក្រុមការងារដែលនៅទីនោះ ហើយមានអ្នករត់រួច និងមានអ្នករត់មិនរួច ត្រូវបានឈ្មោះ [redacted] សារិន និងកូនឈ្មោះ [redacted] សេរីរ័ត្ន ឈ្មោះ [redacted] សេរីវុឌ្ឍ ឈ្មោះ [redacted] ឈុនឡេង ឈ្មោះ [redacted] សុគុណ ឈ្មោះ [redacted] ឆៃគី ឈ្មោះ [redacted] សេង និងបក្ខពួកមួយចំនួនទៀត បានចាប់ឈ្មោះ [redacted] សុវណ្ណ និងម្នាក់ទៀតឈ្មោះ [redacted] ជឿប ចាប់ដាក់ឡាន ។ ខ្ញុំក៏បានឱ្យឈ្មោះ [redacted] សំបូរ មកវិញ ដោយខ្ញុំជិះឡានផ្សេង ចំណែកឈ្មោះ [redacted] សំបូរ ជិះឡានផ្សេង ហើយខ្ញុំបាននាំគ្នាតាមរក និងបានរាយការណ៍ទៅប៉ុស្តិ៍នគរបាល ។ ចំពោះការវាយធ្វើបាបមកលើក្រុមការងារយាមដីខ្ញុំពីក្រុមរបស់ឈ្មោះ [redacted] អ៊ុច គឺខ្ញុំដឹងហេតុការណ៍តាមទូរស័ព្ទគេរាយការណ៍ប្រាប់ ដោយក្រុមការងារបានប្រាប់ថាមានការវាយដំ និងលួចយកទូរស័ព្ទផងដែរ ។ កន្លងមកខ្ញុំធ្លាប់មានជម្លោះជាមួយឈ្មោះ [redacted] សារិន រឿងប្តឹងផ្តល់គ្នាពាក់ព័ន្ធជាមួយរឿងដីទីតាំងនៅកន្លែងកើតហេតុ ។

-សាក្សីឈ្មោះ [redacted] សំបូរ បានឆ្លើយថា នៅថ្ងៃទី១៥ ខែមីនា ឆ្នាំ២០២១ នៅម៉ោង១២ពេលថ្ងៃ ខ្ញុំបាទនៅឈរមើលត្រាក់ទ័រភ្ជួរដីឱ្យឈ្មោះ [redacted] សារីន ហើយមានក្រុមរបស់ឈ្មោះ [redacted] អ៊ុច ឈ្មោះ [redacted] សារិន ឈ្មោះ [redacted] សេរីរ័ត្ន ឈ្មោះ [redacted] សេរីវុឌ្ឍ ឈ្មោះ [redacted] សេង ឈ្មោះ [redacted] ឆៃគី និងឈ្មោះ [redacted] សុគុណ ពេលនោះឈ្មោះ [redacted] អ៊ុច បានហាមឃាត់ឱ្យម្ចាស់ត្រាក់ទ័រឈប់ភ្ជួរដីទៀត និងបានប្រាប់ទៅឈ្មោះ [redacted] សេរីរ័ត្ន និងឈ្មោះ [redacted] សេរីវុឌ្ឍ ថាបើមានអ្នកណានៅតែភ្ជួរដីទៀត ហ្អែងវាយដាក់ឡានទុកឱ្យអញ ហើយខ្ញុំបានប្រាប់ទៅឈ្មោះ [redacted] សេរីរ័ត្ន និងឈ្មោះ [redacted] សេរីវុឌ្ឍ កុំធ្វើតាមមិនល្អទេ ។ ខ្ញុំបានថតជាវីដេអូដែលមិនបានឃើញរូបភាពទេគឺឮតែសម្លេង ដោយសារខ្ញុំដាក់ទូរស័ព្ទនៅក្នុងហោប៉ៅអាវខាងមុខ ទើបវាបាំងកាំម៉េរ៉ា ពេលនោះឈ្មោះ [redacted] អ៊ុច និងខ្ញុំបានដើរបុកស្មាគ្នាទៅវិញទៅមកផងដែរ ។ លុះដល់ម៉ោង១៣ និង៤០នាទី ទើបខ្ញុំបានជិះឡានត្រឡប់ទៅទីរួមខេត្តសៀមរាបវិញ ក្រោយមកឈ្មោះ [redacted] សារីន បានទូរស័ព្ទប្រាប់ខ្ញុំថាក្រុមឈ្មោះ [redacted] អ៊ុច បានចាប់ឈ្មោះ [redacted] សុវណ្ណ និងឈ្មោះ [redacted] ជឿប ដាក់ចូលក្នុងឡានយកទៅបាត់ហើយមិនដឹងយកទៅណាទេ ។

-សាក្សីឈ្មោះ [redacted] កុសល បានឆ្លើយ នៅថ្ងៃទី១៥ ខែមីនា ឆ្នាំ២០២១ ខ្ញុំជាភ្ជួរដីឱ្យឈ្មោះ [redacted] សារីន នៅវេលាម៉ោងប្រហែល៩ព្រឹក ពេលដែលខ្ញុំកំពុងតែភ្ជួរដី ស្រាប់តែមានក្រុមឈ្មោះ [redacted] អ៊ុច ឈ្មោះ [redacted] សារិន ឈ្មោះ [redacted] សេរីរ័ត្ន និងឈ្មោះ [redacted] សេរីវុឌ្ឍ និងមានបក្ខពួកសរុបប្រហែលជា១០នាក់ បានមកហាម

ឃាត់អាត្រាក់ទ័រខ្ញុំ បើមិនឈប់ភ្ជួរទេ ពួកគេនឹងយកសាំងមកដុតអាត្រាក់នេះចោល ដោយដៃមានកាន់សាំងមួយដបមួយលីត្រនៅនឹងដៃ ព្រមទាំងមានដែកកេសផងដែរ ហើយពួកគេបានត្រឡប់ទៅវិញ ។ លុះដល់ម៉ោង១២ មានឈ្មោះ [redacted]អ៊ុច ឈ្មោះ [redacted] សារិន បានជិះម៉ូតូមកជាមួយក្រុមការងារគាត់ប្រហែលជា១៥នាក់បានមកឃាត់ម្តងទៀត ពេលនោះខ្ញុំនៅជាមួយឈ្មោះ [redacted]សំបូរ រហូតដល់ឈ្មោះ [redacted]អ៊ុច និងឈ្មោះ [redacted] សំបូរ បានយកស្មារុញគ្នាទៅវិញទៅមក ឈ្មោះ [redacted]អ៊ុច បាននិយាយថាអាណាខ្លាំង ខ្ញុំអង្គុយលើអាត្រាក់ទ័រនៅចាំតែស្លាប់ ។ លុះដល់ម៉ោង៤ជាងពេលល្ងាច មានឈ្មោះ [redacted] អ៊ុច ឈ្មោះ [redacted] សារិន បានមកហាមឃាត់ខ្ញុំ ដោយនិយាយថាបើនៅភ្ជួរទៀត ពួកគេនឹងដុតអាត្រាក់ទ័រខ្ញុំចោល ពេលនោះឈ្មោះ [redacted] សឿត ឈ្មោះ [redacted] ធឿប ឈ្មោះ [redacted] សុវណ្ណ បានមកដល់ ហើយបក្ខពួកខាងឈ្មោះ [redacted]អ៊ុច ឈ្មោះ [redacted] សារិន ក៏បានមកដល់ដែរ ខ្ញុំស្គាល់ឈ្មោះ [redacted] សេរីវត្ត ឈ្មោះ [redacted] សេរីវុឌ្ឍ ឈ្មោះ [redacted] ឆៃគី ឈ្មោះ [redacted] សុគុណ និងឈ្មោះ [redacted] សេង បាននាំគ្នាដេញចាប់ឈ្មោះ [redacted] សឿត ឈ្មោះ [redacted] ធឿប ឈ្មោះ [redacted] សុវណ្ណ ដាក់ឡាន ប៉ុន្តែចាប់បានតែឈ្មោះ [redacted] ធឿប ឈ្មោះ [redacted] សុវណ្ណ ខ្ញុំឃើញផ្ទាល់នឹងភ្នែកមិនដឹងថាអ្នកណាអ្នកចាប់នោះទេ បានចាប់គ្រៀក ច្របាច់កចូលឡាន ។ ចំណែកខ្ញុំបានរត់គេចខ្លួនទៅទិសខាងកើត ហើយឈ្មោះ [redacted] សឿត រត់ទៅទិសខាងជើង ។ ក្រុមរបស់ឈ្មោះ [redacted]អ៊ុច ទៅជិះឡានចំនួន២គ្រឿង ពណ៌ខ្មៅ១គ្រឿង ពណ៌ស១គ្រឿង នៅក្នុងឡានមានមនុស្សប៉ុន្មាននាក់ខ្ញុំមិនច្បាស់ទេ ពីព្រោះខ្ញុំរត់ចេញពីទីនោះប្រហែល២០ម៉ែត្រ ។ ពេលនោះខ្ញុំមិនបានតតាំង ឬថតពួកគេនោះទេ ពីព្រោះខ្ញុំគ្មានទូរស័ព្ទទេ ។ ខ្ញុំដឹងថាពួកគាត់ឈ្លោះគ្នារឿងដីធ្លី ។ ខ្ញុំឃើញមានឈ្មោះ [redacted] សឿត ឈ្មោះ [redacted] ធឿប ឈ្មោះ [redacted] សុវណ្ណ និងឈ្មោះ [redacted]យ៉ា មានប្រើទូរស័ព្ទម្នាក់១គ្រឿង ហើយក្នុងពេលនោះ ក្រុមរបស់ឈ្មោះ ម៉ៅ អ៊ុច បាននាំគ្នារត់ដេញចាប់ដកហូតយកទូរស័ព្ទពីឈ្មោះ [redacted] សុវណ្ណ ឈ្មោះ [redacted] ធឿប និងឈ្មោះ [redacted] សឿត តែម្តង។ ចំពោះឈ្មោះ [redacted]អ៊ុច មិនបានចាប់មនុស្សដាក់ឡានទេ គឺអ្នកផ្សេង ឈ្មោះ [redacted]អ៊ុច ទៅដែរ មិនបានចុះពីឡានទេ អ្នកដែលបញ្ជាឱ្យចាប់មនុស្សដាក់ឡានឈ្មោះ [redacted] សារិន ។ ពេលក្រុមរបស់ឈ្មោះ [redacted]អ៊ុច បានចាប់ឈ្មោះ [redacted]សុវណ្ណ និងឈ្មោះ [redacted]ធឿប ចូលឡាន ហើយបានបើកឡានចេញ ខ្ញុំបានត្រឡប់មកវិញពីព្រោះអាត្រាក់ទ័រខ្ញុំនៅជិតឡាននោះដែរ ។

-សាក្សីឈ្មោះ [redacted]ប៊ុនរ៉ុង បានឆ្លើយថា នៅថ្ងៃទី១៥ ខែមីនា ឆ្នាំ២០២១ វេលាម៉ោង១៦ និង២០នាទីខ្ញុំកំពុងនៅសហគមន៍បឹងឈូក កំពុងតែធ្វើការស្រាប់តែមានមនុស្សពីរនាក់មកសុំខ្ចីប្រេងកូឡាលាបទៅលើស្មា និងខ្ចីទូរស័ព្ទតេទៅបងប្អូនគាត់ ដោយមិនបានប្រាប់រឿងអីមកខ្ញុំនោះទេ ។

-សាក្សីឈ្មោះ [redacted]កន់ បានឆ្លើយថា ខ្ញុំស្គាល់ឈ្មោះ [redacted]សុគុណ ជាអ្នករស់នៅក្នុងភូមិជាមួយខ្ញុំ ហើយនៅថ្ងៃទី១៥ ខែមីនា ឆ្នាំ២០២១ គឺមានបុណ្យភូមិ ហើយផ្ទះខ្ញុំបាទធ្វើនំបញ្ចុក ហើយឈ្មោះ [redacted]សុគុណ បានមកជួយធ្វើនំបញ្ចុកជាមួយខ្ញុំចាប់ពីម៉ោង៤ល្ងាច រហូតដល់៦ល្ងាច ។ មុនម៉ោង៤ល្ងាច ខ្ញុំមិនដឹងថាឈ្មោះ [redacted] សុគុណ នៅទីណាទេ ។ ក្រោយមកមានគេនិយាយពីរឿងរ៉ាវទំនាស់ដីធ្លីដែរ ប៉ុន្តែមិនដឹងអ្នកណាមានទំនាស់ជាមួយអ្នកណា ខ្ញុំមិនដឹងទេ ។

-សាក្សីឈ្មោះ [redacted]ពៅ បានឆ្លើយថា ឈ្មោះ [redacted]សុគុណ ជាអ្នកភូមិរស់នៅក្បែរផ្ទះខ្ញុំ នៅថ្ងៃទី១៥ ខែមីនា ឆ្នាំ២០២១ គឺខ្ញុំបានឱ្យឈ្មោះ [redacted] សុគុណ ជួយជួសជុលម៉ូតូឱ្យខ្ញុំ ដោយខ្ញុំយកម៉ូតូទៅដាក់ឱ្យឈ្មោះ គង់ សុគុណ នៅម៉ោង៣រសៀល រហូតដល់ម៉ោង៥ល្ងាចទើបជួសជុលរួច ហើយឈ្មោះ [redacted]សុគុណ បានមកជួយរ៉ោយនំបញ្ចុកឱ្យខ្ញុំផងដែរ ពីព្រោះមានបុណ្យភូមិ ហើយផ្ទះខ្ញុំបានធ្វើនំបញ្ចុក ហើយ

ឈ្មោះ [redacted] សុគុណ បានមកជួយខ្ញុំរហូតដល់ម៉ោង៧ពេលយប់ ដោយជួយរត់តុ និងបំរើភ្ញៀវផងដែរ ខ្ញុំធ្វើបុណ្យភូមិមានរយៈពេល៣ថ្ងៃ ។ ថ្ងៃធ្វើបុណ្យភូមិត្រូវនឹងថ្ងៃខ្មែរ ១កើត ២កើត និង៣កើត ។

-សាក្សីឈ្មោះ [redacted] **សាភេន** បានឆ្លើយថា នៅថ្ងៃទី១៥ ខែមីនា ឆ្នាំ២០២១ ខ្ញុំរៀបការឱ្យកូននៅភូមិអូរម្កាស់ ស្រុកបន្ទាយស្រី ។ ចំពោះរឿងទំនាស់គ្នានៅថ្ងៃទី១៥ ខែមីនា ឆ្នាំ២០២១ ខ្ញុំមិនបានដឹងទេ។ នៅថ្ងៃទី១៥ ខែមីនា ឆ្នាំ២០២១ ខ្ញុំឃើញឈ្មោះ [redacted] សារិន បានអញ្ជើញមកចូលរួមហូបការកូននាងខ្ញុំជាមួយឈ្មោះ ឡេង ត្រកូលគាត់ខ្ញុំមិនស្គាល់ទេ ក្រៅពីនោះមិនមានអ្នកណាទៅជាមួយទេ ។ ឈ្មោះ [redacted] សារិន មកដល់រោងការប្រហែលម៉ោង២ ជិត៣ ពេលរសៀល ។ ពីធីការចាប់ទទួលភ្ញៀវពីម៉ោង១១ព្រឹក ដល់ម៉ោង៥ល្ងាច ទាល់តែម៉ោង២ ទើបមានភ្ញៀវចូលហូប ។ ឈ្មោះ [redacted] សារិន នៅហូបការរហូតដល់ម៉ោង៥ ខ្ញុំមិនបានអង្គុយតុជាមួយគាត់ទេពីព្រោះខ្ញុំនៅទទួលភ្ញៀវ នៅម៉ោង៦ល្ងាចទើបឈ្មោះ [redacted] សារិន ចេញទៅវិញ ។ ខ្ញុំបានជួបឈ្មោះ [redacted] សារិន ម្តងទៀតនៅម៉ោង៤ អង្គុយជាមួយគាត់បានម្តង ។ ពីផ្ទះការទៅភូមិលៀប ឃុំពាក់ស្នែង ខ្ញុំដឹងមិនថាចម្ងាយប៉ុន្មានគីឡូម៉ែត្រនោះទេ ។ ខ្ញុំមិនមានរូបថតរបស់ឈ្មោះ [redacted] សារិន និងឈ្មោះ ឡេង ថតជាមួយកូនកំលោះនិងកូនក្រមុំទេ ពីព្រោះពួកគាត់មិនបានថតទេ ។

## សេចក្តីសន្និដ្ឋានរបស់មេធាវីការពារក្តីឱ្យដើមបណ្តឹងរដ្ឋប្បវេណី

លោក [redacted] បានធ្វើសេចក្តីសន្និដ្ឋានថា ឆ្លងតាមកិច្ចពិភាក្សាដេញដោលនាពេលសវនាការនោះ និងក្រោយពីបានស្តាប់ចម្លើយជនជាប់ចោទឈ្មោះ [redacted] សេង ឈ្មោះ [redacted] សារិន ឈ្មោះ [redacted] សេរីវត្ថ ឈ្មោះ [redacted] សេរីវុឌ្ឍ ឈ្មោះ [redacted] សុគុណ ឈ្មោះ [redacted] អ៊ុច ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី និងចម្លើយសាក្សី ឃើញថាជនត្រូវចោទឈ្មោះ [redacted] សេង ឈ្មោះ [redacted] សារិន ឈ្មោះ [redacted] សេរីវត្ថ ឈ្មោះ [redacted] សេរីវុឌ្ឍ ឈ្មោះ [redacted] សុគុណ ឈ្មោះ [redacted] ឆៃគី និងឈ្មោះ [redacted] អ៊ុច ពិតជាបានប្រព្រឹត្តបទល្មើស ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោស បទល្មើស ចាប់ដោយខុសច្បាប់ បទល្មើស គំរាមកំហែងថានឹងសម្លាប់ដោយមានបញ្ជាឱ្យបំពេញលក្ខខណ្ឌ បទល្មើស ធ្វើឱ្យខូចខាតដោយចេតនា និងបទល្មើស លុបបំបាត់វត្ថុតាង ប្រព្រឹត្តនៅភូមិលៀប ឃុំពាក់ស្នែង ស្រុកអង្គរធំ ខេត្តសៀមរាប កាលពីថ្ងៃទី១៥ ខែមីនា ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌដែលមានចែងនិងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា**២១៨ មាត្រា២៥៣ ចំណុច១ មាត្រា២៣៤ មាត្រា៤១០ មាត្រា៤១១ និងមាត្រា៥៣៣** នៃក្រមព្រហ្មទណ្ឌ ពីព្រោះនៅកើតហេតុនៅថ្ងៃទី១៥ ខែមីនា ឆ្នាំ២០២១ វេលាម៉ោង ១៦ និង១០នាទី ឈ្មោះ [redacted] សឿត និងឈ្មោះ [redacted] ប៉ឿប ឈ្មោះ [redacted] យ៉ា និងឈ្មោះ [redacted] សុវណ្ណ បានទៅមើលត្រាក់ទ័រភ្ជួរដី ស្ថិតក្នុងតំបន់អូរកន្សែង ស្ថិតនៅភូមិលៀប ឃុំពាក់ស្នែង ស្រុកអង្គរធំ ខេត្តសៀមរាប ក៏ត្រូវបានក្រុមខាងលើធ្វើសកម្មភាពដូចរៀបរាប់នៅក្នុងអង្គសវនាការ ដូចជាការចាប់ព័ទ្ធស្លាបសេក ឡើងជង្គង់ ចាប់ដាក់ចូលក្នុងឡាន ហើយនៅក្នុងនោះពួកគេបានដកហូតយកទូរស័ព្ទអស់ចំនួន៤គ្រឿង ជិះរហូតដល់ស្រះឈូក ហើយមេក្រុមឈ្មោះ [redacted] អ៊ុច ដែលនៅទីនោះ បានគម្រាមកំហែងថាបើនៅតែចូលទៅក្នុងទីតាំងដីនោះទៀត ពួកគេនឹងសម្លាប់ចោលទាំងគ្រួសារ ។ នៅក្នុងនេះផងដែរសាក្សីក៏បានឆ្លើយបញ្ជាក់រួចហើយដែរ ។ បើយើងពិនិត្យមើលជាតុផ្សំនៃបទល្មើសឃើញថាមានធាតុផ្សំគ្រប់គ្រាន់ ហេតុដូច្នេះស្នើសុំឱ្យលោកស្រីប្រធានក្រុមប្រឹក្សាជំនុំជម្រះពិចារណា និងសម្រេចផ្តន្ទាទោសតាមច្បាប់ ។

## សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ

ក្រោយពីបានស្តាប់ការសួរដេញដោលនៅក្នុងអង្គសវនាការ ឃើញថានៅក្នុងសំណុំរឿងនេះដែរ តំណាងអយ្យការបានចោទប្រកាន់ជនជាប់ចោទចំនួន៨នាក់ តាមជីកាដំណោះស្រាយ ក្នុងនោះមានជន



Scanned with CamScanner

ជាប់ចោទឈ្មោះ [redacted] សេង ឈ្មោះ [redacted] សារិន ឈ្មោះ [redacted] សុគុណ ឈ្មោះ [redacted] ស៊ិក ឈ្មោះ [redacted] ពិត ឈ្មោះ [redacted] រឿត ឈ្មោះ [redacted] សេរីរ័ត្ន ឈ្មោះ [redacted] សេរីវុឌ្ឍ ឈ្មោះ [redacted] ឈុនឡេង ឈ្មោះ [redacted] ឆៃគី និង ឈ្មោះ [redacted] អ៊ិច ប៉ុន្តែដោយសារសំណុំរឿងនេះគឺមានសំណុំរឿងពីរបញ្ចូលគ្នា ហើយនៅក្នុងសំណុំរឿងនេះដែរ តំណាងអយ្យការសូមបញ្ជាក់ថា យើងពិនិត្យអង្គហេតុនឹងការចោទប្រកាន់គឺនៅថ្ងៃទី១៥ ខែមីនា ឆ្នាំ ២០២១ តាមការសួរដេញដោលនាពេលសវនាការឃើញថា មានអង្គហេតុច្រើនតាមការសាកសួរ ប៉ុន្តែអ្វីដែរយកមកជំនុំជម្រះនាពេលនេះ គឺផ្តោតសំខាន់ទៅលើអង្គហេតុនៅថ្ងៃទី១៥ ខែមីនា ឆ្នាំ២០២១ ហើយនៅក្នុងអង្គហេតុនេះដែរ តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] សេង ឈ្មោះ [redacted] សារិន ឈ្មោះ [redacted] សុគុណ ឈ្មោះ [redacted] សេរីរ័ត្ន ឈ្មោះ [redacted] សេរីវុឌ្ឍ និងឈ្មោះ [redacted] ឈុនឡេង ដែលមានវត្តមាននាពេលនេះ សុទ្ធតែឆ្លើយបដិសេធទាំងអស់ថា ពួកគាត់មិនបានប្រព្រឹត្តដូចការចោទប្រកាន់ទេ ប៉ុន្តែតំណាងអយ្យការយល់ឃើញថាការឆ្លើយនេះគ្រាន់តែជាចម្លើយដោះសារទេ ដោយផ្អែកថានៅក្នុងសំណុំរឿងនេះ អង្គសវនាការបានសួរពាក់ព័ន្ធនឹងចម្លើយដើមបណ្តឹងរដ្ឋប្បវេណីចំនួន៤នាក់ ដែលមានឈ្មោះ [redacted] សុវណ្ណ ឈ្មោះ [redacted] យ៉ា ឈ្មោះ [redacted] រឿប និងឈ្មោះ [redacted] សឿត បានឆ្លើយថាជនជាប់ចោទទាំង៨នាក់ លើកលែងតែជនជាប់ចោទ៣នាក់មានឈ្មោះ [redacted] ស៊ិក ឈ្មោះ [redacted] ពិត ឈ្មោះ [redacted] រឿត ដែលមិនបានចូលរួមទេនៅក្នុងអង្គហេតុនៅថ្ងៃទី១៥ ខែមីនា ឆ្នាំ២០២១ នេះ ប៉ុន្តែជនជាប់ចោទទាំង៣នាក់នេះមានការពាក់ព័ន្ធនឹងអង្គហេតុនៅក្នុងថ្ងៃផ្សេងវិញ ក្រៅពីនោះជនជាប់ចោទទាំង៨នាក់ ដក៣នាក់ចេញ សុទ្ធតែបានប្រព្រឹត្តអំពើ ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោស អំពើ ចាប់ដោយខុសច្បាប់ អំពើ គំរាមកំហែងថានឹងសម្លាប់ដោយមានបញ្ជាឱ្យបំពេញលក្ខខណ្ឌ អំពើ ធ្វើឱ្យខូចខាតដោយចេតនា និងអំពើ លុបបំបាត់វត្ថុតាង បើយើងពិនិត្យមើលចម្លើយសាក្សីនាពេលសវនាការ ឃើញថាមានចម្លើយសាក្សីទាំងដោះបន្ទុក និងដាក់បន្ទុក ។ ចំពោះចម្លើយសាក្សីដាក់បន្ទុកសុទ្ធឆ្លើយអះអាងថាជនជាប់ចោទ៨នាក់ខាងលើ ពិតជាបានធ្វើសកម្មភាពដូចការចោទប្រកាន់ប្រាកដមែន ដោយបានចាប់ឈ្មោះ [redacted] សុវណ្ណ ឈ្មោះ [redacted] ជឿប ដាក់បញ្ចូលឡាន ព្រមទាំងបានដកហូតយកទូរស័ព្ទ ព្រមទាំងមានអង្គហេតុគំរាមកំហែងថានឹងសម្លាប់ ប៉ុន្តែក៏មានសាក្សីមួយចំនួនដែរ ឈ្មោះ ឃៀង សាភេន បានឆ្លើយថានៅថ្ងៃកើតហេតុមានឈ្មោះ [redacted] សារិន ឈ្មោះ [redacted] ឈុនឡេង បានអញ្ជើញចូលរួមហូបការនៅថ្ងៃទី១៥ ខែមីនា ឆ្នាំ២០២១ ហើយតំណាងអយ្យការបានសួរបញ្ជាក់ហើយបញ្ជាក់ទៀតថា តើនៅថ្ងៃទី១៥ ខែមីនា ឆ្នាំ២០២១ ឈ្មោះ [redacted] សារិន ឈ្មោះ [redacted] ឈុនឡេង បានអញ្ជើញចូលរួមហូបការឬទេ? សាក្សីឈ្មោះ [redacted] សាភេន បានឆ្លើយថាពួកគាត់ពិតជាបានចូលរួម ហើយតំណាងអយ្យការធ្វើការកត់សំគាល់ថាសាក្សីនេះគាត់ឆ្លើយច្បាស់ពេក ហើយគាត់ឆ្លើយថាថ្ងៃការឈ្មោះ [redacted] សារិន ឈ្មោះ [redacted] ឈុនឡេង នៅហូបការរហូត ហើយនៅក្នុងចំណោមជនជាប់ចោទទាំង៨នាក់ គឺមានអ្នកទៅចូលរួមហូបការមានតែ២នាក់ទេគឺឈ្មោះ [redacted] សារិន ឈ្មោះ [redacted] ឈុនឡេង ប៉ុន្តែភ្លេចគិតចម្លើយរបស់ឈ្មោះ [redacted] សារិន ឈ្មោះ ស៊ិនសេរីរ័ត្ន ឈ្មោះ [redacted] សេរីវុឌ្ឍ និងឈ្មោះ [redacted] ឈុនឡេង បានឆ្លើយច្បាស់ណាស់ថាទៅហូបការមានគ្នា៤នាក់ ជិះឡានជាមួយឈ្មោះ [redacted] ឈុនឡេង ទៀត រឿងអីសាក្សីឃើញតែគ្នា២នាក់ ហេតុដូច្នេះសូមឱ្យអង្គសវនាការពិនិត្យថាចម្លើយរបស់សាក្សីពុំមានភាពជឿជាក់បានទេ ។ ដោយឡែកសាក្សីឈ្មោះ [redacted] ភន បានឆ្លើយថាជនជាប់ចោទឈ្មោះ [redacted] សុគុណ នៅថ្ងៃទី១៥ ខែមីនា ឆ្នាំ២០២១ គាត់នៅធ្វើនំបញ្ចុក និងជួសជុលម៉ូតូ គឺសាក្សីរូបនេះគាត់ឆ្លើយមិនច្បាស់ថាឈ្មោះ [redacted] សុគុណ ធ្វើនំបញ្ចុក ឬក៏ជួសជុលម៉ូតូ នៅថ្ងៃតែមួយធ្វើនំបញ្ចុកផង ជួសជុលម៉ូតូផង ឥលូវធ្វើអ្វីឱ្យប្រាកដ តើធ្វើមួយណា? ចំពោះចម្លើយសាក្សីឈ្មោះ [redacted] ពៅ



Scanned with CamScanner

បញ្ជាក់ថាឈ្មោះ [redacted] សុគុណ គាត់នៅជួយធ្វើនំបញ្ចុកទេ បែរជាសាក្សីឈ្មោះ [redacted] កន់ ថាជួសជុលម៉ូតូទៅវិញ ហើយថាទៅជួយធ្វើបុណ្យទៀត តើថ្ងៃនឹងសកម្មភាពទាំងបីនឹងទៅកន្លែងណា? ធ្វើនំបញ្ចុក ជួសជុលម៉ូតូ ជួយរត់គុបុណ្យ តើមនុស្សម្នាក់អាចធ្វើសកម្មភាពបីក្នុងពេលតែមួយបានទេ? ត្រង់ចំណុចនេះ សូមអង្គសវនាការធ្វើការពិចារណា ។ នៅក្នុងសំណុំរឿងនេះឃើញថាមានជាតុផ្សំគ្រប់គ្រាន់ក្នុងការចោទប្រកាន់ ដើម្បីចោទប្រកាន់ជនជាប់ចោទទាំង៨នាក់ មានតែ២បទល្មើសទេគឺ ពីបទ ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោសតាមបញ្ញត្តិមាត្រា២១៨ នៃក្រមព្រហ្មទណ្ឌ ពីបទ គំរាមកំហែងថានឹងសម្លាប់ដោយមានបញ្ជាឱ្យបំពេញលក្ខខណ្ឌតាមបញ្ញត្តិមាត្រា២៣៣ នៃក្រមព្រហ្មទណ្ឌ និងពីបទ ធ្វើឱ្យខូចខាតដោយចេតនាដោយឡែកចំពោះអង្គតាមបញ្ញត្តិមាត្រា ៤១០ និងមាត្រា៤១១ នៃក្រមព្រហ្មទណ្ឌ ។ ហេតុដូច្នេះតំណាងអយ្យការប្តឹងសុំប្រធានក្រុមប្រឹក្សាជំនុំជម្រះសម្រេចផ្តន្ទាទោសជនជាប់ចោទតាមច្បាប់ ។

## សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ

លោកមេធាវី [redacted] បានធ្វើសេចក្តីសន្និដ្ឋានថា ឆ្លងតាមការសួរដេញដោលនាពេលសវនាការ យោងតាមចម្លើយបដិសេធរបស់កូនក្តីខ្ញុំបាទ ចម្លើយសាក្សី ព្រមទាំងភស្តុតាងនានា គឺមានភាពស៊ីសង្វាក់គ្នាដែលបញ្ជាក់ថា កូនក្តីខ្ញុំបាទឈ្មោះ [redacted] សារិន ឈ្មោះ [redacted] ឆៃគី ឈ្មោះ [redacted] សុគុណ ឈ្មោះ [redacted] សេរីវុឌ្ឍ ឈ្មោះ [redacted] បវរ័ត្ន ឈ្មោះ [redacted] ឈុនឡេង ពុំបានប្រព្រឹត្តបទល្មើសដូចការចោទប្រកាន់ទេ ហេតុនេះសំណូមពរដល់លោកចៅក្រម មេត្តាឱ្យកូនក្តីខ្ញុំបាទរួចខ្លួនពីបទ ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោស បទ ចាប់ដោយខុសច្បាប់ បទ គំរាមកំហែងថានឹងសម្លាប់ដោយមានបញ្ជាឱ្យបំពេញលក្ខខណ្ឌ បទ ធ្វើឱ្យខូចខាតដោយចេតនា និង បទ លុបបំបាត់វត្ថុតាង ប្រព្រឹត្តនៅភូមិលៀប ឃុំពាក់ស្នែង ស្រុកអង្គរធំ ខេត្តសៀមរាប កាលពីថ្ងៃទី១៥ ខែមីនា ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌដែលមានចែងនិងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា២១៨ មាត្រា២៥៣ ចំណុច១ មាត្រា២៣៤ មាត្រា៤១០ មាត្រា៤១១ និងមាត្រា៥៣៣ នៃក្រមព្រហ្មទណ្ឌ ។

## សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ

មេធាវី [redacted] បានធ្វើសេចក្តីសន្និដ្ឋានថា ស្នើសុំឱ្យកូនក្តីខ្លួនឈ្មោះ [redacted] សេង រួចផុតពីបទចោទតាមបញ្ញត្តិមាត្រា១១០ មាត្រា៣៥០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ និងមាត្រា៣៨ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ។

## សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ

មេធាវី [redacted] បានធ្វើសេចក្តីសន្និដ្ឋានថា ស្នើសុំឱ្យកូនក្តីខ្លួនឈ្មោះ [redacted] អ៊ិច រួចផុតពីបទចោទតាមបញ្ញត្តិមាត្រា១១០ មាត្រា៣៥០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ និងមាត្រា៣៨ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ។

## សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ

-ឈ្មោះ [redacted] សារិន ស្នើសុំលោកស្រីប្រធានក្រុមប្រឹក្សាជំនុំជម្រះមេត្តាឱ្យខ្ញុំបាទ រួចផុតពីបទចោទ ។

-ឈ្មោះ [redacted] ឈុនឡេង ស្នើសុំលោកស្រីប្រធានក្រុមប្រឹក្សាជំនុំជម្រះមេត្តាឱ្យខ្ញុំបាទ រួចផុតពីបទចោទ ។

-ឈ្មោះ [redacted] សេរីរ័ត្ន ស្នើសុំលោកស្រីប្រធានក្រុមប្រឹក្សាជំនុំជម្រះមេត្តាឱ្យខ្ញុំបាទ រួចផុតពីបទចោទ ។

-ជនជាប់ចោទឈ្មោះ [redacted] សរីវុឌ្ឍ ស្នើសុំលោកស្រីប្រធានក្រុមប្រឹក្សាជំនុំជម្រះមេត្តាឱ្យខ្ញុំបាទ រួចផុតពីបទចោទ ។



Scanned with CamScanner

-ជនជាប់ចោទឈ្មោះ [redacted]សុគុណ ស្នើសុំលោកស្រីប្រធានក្រុមប្រឹក្សាជំនុំជម្រះមេត្តាឱ្យខ្ញុំបាទ រួចផុតពីបទចោទ ។

-ជនជាប់ចោទឈ្មោះ [redacted]សង ស្នើសុំលោកស្រីប្រធានក្រុមប្រឹក្សាជំនុំជម្រះមេត្តាឱ្យខ្ញុំបាទ រួចផុតពីបទចោទ ។

-ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ

-ក្រោយពីបានស្តាប់ចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី

-ក្រោយពីបានស្តាប់ចម្លើយរបស់សាក្សី

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវី

-ក្រោយពីបានពិនិត្យកស្តុតាង និងពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

## សំអាងហេតុ

**តាមលទ្ធផលនៃកិច្ចពិភាក្សាដេញដោល និងពិនិត្យកស្តុតាងនាពេលសវនាការឃើញថា៖**

១-តុលាការបានទទួលជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខ ៩៦៣ ចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០២១ និងសំណុំរឿងព្រហ្មទណ្ឌលេខ ៤៣៧ ចុះថ្ងៃទី០១ ខែឧសភា ឆ្នាំ២០២១ ដែលមានដីកាសម្រេចបញ្ចូលសំណុំរឿងតែមួយលេខ ១១៨ រប/២៣ ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ២០២៣ តុលាការយកសំណុំរឿងទាំង២មក ជំនុំជម្រះនៅថ្ងៃទី០៩ ខែសីហា ឆ្នាំ២០២៣ ។

២-ផ្អែកតាមសំណុំរឿងព្រហ្មទណ្ឌលេខ ៤៣៧ ចុះថ្ងៃទី០១ ខែឧសភា ឆ្នាំ២០២១ ដែលមានដីកាដំណោះស្រាយលេខ ៤៧៤៦ ពស.ព្រស/ជ ចុះថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០២១ សម្រេចបញ្ជូនលើកលែងចោទប្រកាន់លើជនត្រូវចោទឈ្មោះ [redacted]ស៊ុក ឈ្មោះ [redacted]ក ឈ្មោះ [redacted]រឿត ពីបទ ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោស ចាប់ដោយខុសច្បាប់ គំរាមកំហែងថានឹងសម្លាប់ដោយមានបញ្ជាឱ្យបំពេញលក្ខខណ្ឌ ធ្វើឱ្យខូចខាតដោយចេតនាមានស្ថានទម្ងន់ទោស លុបបំបាត់វត្ថុតាង ប្រព្រឹត្តនៅចំណុចភូមិលៀប ឃុំពាក់ស្នែង ស្រុកអង្គរធំ ខេត្តសៀមរាប កាលពីថ្ងៃទី១៥ ខែមីនា ឆ្នាំ២០១១ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា២១៨ មាត្រា២៥៣ ចំណុច១ មាត្រា២៣៤ មាត្រា៤១០ មាត្រា៤១១ និងមាត្រា៥៣៣ នៃក្រមព្រហ្មទណ្ឌ និងសម្រេចបញ្ជូនទៅជំនុំជម្រះលើឈ្មោះ [redacted]សារិន ឈ្មោះ [redacted]សេរីវុឌ្ឍ ឈ្មោះ [redacted]សេរីវត្ត ឈ្មោះ [redacted]ឈុនឡេង ឈ្មោះ [redacted]សុគុណ ឈ្មោះ [redacted]ធគី ឈ្មោះ [redacted]សង និងឈ្មោះ [redacted]អ៊ុច ពីបទ ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោស ចាប់ដោយខុសច្បាប់ គំរាមកំហែងថានឹងសម្លាប់ដោយមានបញ្ជាឱ្យបំពេញលក្ខខណ្ឌ ធ្វើឱ្យខូចខាតដោយចេតនាមានស្ថានទម្ងន់ទោស លុបបំបាត់វត្ថុតាង ប្រព្រឹត្តនៅចំណុចភូមិលៀប ឃុំពាក់ស្នែង ស្រុកអង្គរធំ ខេត្តសៀមរាប កាលពីថ្ងៃទី១៥ ខែមីនា ឆ្នាំ២០១១ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា២១៨ មាត្រា២៥៣ ចំណុច១ មាត្រា២៣៤ មាត្រា៤១០ មាត្រា៤១១ និងមាត្រា៥៣៣ នៃក្រមព្រហ្មទណ្ឌ ។

៣-ផ្អែកតាមសំណុំរឿងព្រហ្មទណ្ឌលេខ ៦៩៣ ចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០២១ ដែលមានដីកាដំណោះស្រាយលេខ ២៣៨៨ ពស.ព្រស/ជ ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ២០២២ សម្រេចបញ្ជូនទៅជំនុំ



Scanned with CamScanner

ជម្រះលើជនត្រូវចោទឈ្មោះ [redacted] សារិន ឈ្មោះ [redacted] សេរីវុឌ្ឍ ឈ្មោះ [redacted] សេរីរត្ន ឈ្មោះ [redacted] ឈុនឡេង ឈ្មោះ [redacted] សុគុណា ឈ្មោះ [redacted] ឆៃគី ឈ្មោះ [redacted] សេង និងឈ្មោះ [redacted] អ៊ិច ពីបទ ហិង្សាដោយចេតនា មានស្ថានទម្ងន់ទោស គំរាមកំហែងថានឹងសម្លាប់ និងលួច ប្រព្រឹត្តនៅចំណុចអូរជ្រៅ ស្ថិតនៅក្នុងភូមិលៀប ឃុំពាក់ស្នែង ស្រុកអង្គរធំ ខេត្តសៀមរាប កាលពីថ្ងៃទី១៥ ខែមីនា ឆ្នាំ២០១១ បទល្មើសព្រហ្មទណ្ឌ ដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា២១៨ មាត្រា២៣៣ មាត្រា៣៥៣ និងមាត្រា៣៥៦ នៃក្រមព្រហ្មទណ្ឌ ។

៤-ផ្អែកតាមសាលដីកាលេខ ៣៩ (ង) ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២២ សម្រេចបញ្ជូនទៅជំនុំជម្រះលើជនត្រូវចោទឈ្មោះ [redacted] សារិន ឈ្មោះ [redacted] សេរីវុឌ្ឍ ឈ្មោះ [redacted] សេរីរត្ន ឈ្មោះ [redacted] ឈុនឡេង ឈ្មោះ [redacted] សុគុណា ឈ្មោះ [redacted] ឆៃគី ឈ្មោះ [redacted] សេង និងឈ្មោះ [redacted] អ៊ិច ពីបទ លួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា និងបទធ្វើឱ្យខូចខាតដោយចេតនា ប្រព្រឹត្តនៅភូមិលៀប ឃុំពាក់ស្នែង ស្រុកអង្គរធំ ខេត្តសៀមរាប កាលពីថ្ងៃទី១៥ ខែមីនា ឆ្នាំ២០១១ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៣៥៣ មាត្រា៣៥៧ មាត្រា៤១០ និងមាត្រា៤១១ នៃក្រមព្រហ្មទណ្ឌ ។

៥-កាលពីថ្ងៃទី១៥ ខែមីនា ឆ្នាំ២០២១ វេលាម៉ោង១៦ និង១០នាទី ដែលមានជនរងគ្រោះឈ្មោះ [redacted] សុវណ្ណ ឈ្មោះ [redacted] ជឿប ឈ្មោះ [redacted] សឿត និងឈ្មោះ [redacted] យ៉ា កំពុងតែឈរមើលត្រាក់ទ័រឈូសដីចំការនៅចំណុចអូរជ្រៅ ស្ថិតនៅក្នុងភូមិលៀប ឃុំពាក់ស្នែង ស្រុកអង្គរធំ ខេត្តសៀមរាប ស្រាប់តែមានថយន្តចំនួន២គ្រឿង ម៉ាក LUXUS LX 470 មិនស្គាល់សេរី(ពាក់ស្លាកលេខ ខ.ភ.ម) មិនចាំលេខ និងមួយគ្រឿងទៀត ពណ៌ខ្មៅ មិនស្គាល់ម៉ាកបានបើកមកឈប់នៅមុខដីចំការ ។ ពេលនោះជនសង្ស័យឈ្មោះ [redacted] សារិន បានចុះពីលើថយន្ត ហើយបានស្រែកគំរាមមិនឱ្យឈូសដីចំការទៀតទេ ។ លុះបានប្រហែល១៥នាទី ឈ្មោះ [redacted] សារិន ឈ្មោះ [redacted] ឆៃគី ឈ្មោះ [redacted] សុគុណា ឈ្មោះ [redacted] ឈុនឡេង ឈ្មោះ [redacted] សេង ឈ្មោះ [redacted] សេរីវឌ្ឍនៈ និងឈ្មោះ [redacted] សេរីរត្ន បានចូលទៅចាប់ជនរងគ្រោះឈ្មោះ [redacted] សុវណ្ណ និងឈ្មោះ [redacted] ជឿប ដាក់ចូលក្នុងឡាន ចំណែកឯឈ្មោះ [redacted] សឿត និងឈ្មោះ [redacted] យ៉ា រត់គេចខ្លួនរួច ហើយជនសង្ស័យឈ្មោះ [redacted] សារិន ឈ្មោះ [redacted] សេរីវឌ្ឍនៈ និងឈ្មោះ [redacted] សេរីរត្ន បាននាំគ្នាដកយកទូរស័ព្ទដៃរបស់ជនរងគ្រោះចំនួន៤គ្រឿង លុយចំនួន ៤០០,០០០ (សែសិបម៉ឺន) រៀល និងវិទ្យុទាក់ទង (អាយគម) ចំនួន០១គ្រឿង និងបានជិះឡាននាំឈ្មោះ [redacted] សុវណ្ណ និងឈ្មោះ [redacted] ជឿប ទៅជួបឈ្មោះ [redacted] អ៊ិច នៅចំណុចស្រះឈូក ស្ថិតនៅក្នុងភូមិបន្ទាយស្រី ឃុំខ្នារសណ្តាយ ស្រុកបន្ទាយស្រី ខេត្តសៀមរាប ហើយឈ្មោះ [redacted] អ៊ិច បានប្រាប់ទៅជនរងគ្រោះថា បើជនរងគ្រោះទៅដាំដីនឹងទៀតរូបគេនិងសម្លាប់ជនរងគ្រោះទាំងគ្រួសារចោល ។ បន្ទាប់មកឈ្មោះ [redacted] អ៊ិច បានយកវិទ្យុទាក់ទង (អាយគម) បោកទៅនឹងឈើបណ្តាលឱ្យបែក មួយសន្ទុះក្រោយមកក្រុមរបស់ឈ្មោះ [redacted] អ៊ិច បានចេញទៅវិញអស់ ហើយឈ្មោះ [redacted] ជឿប និងឈ្មោះ សោម សុវណ្ណ បានដើរចេញមកថ្នល់ក៏ជួបឈ្មោះ [redacted] សំបួរ ក៏នាំទៅប្តឹងសមត្ថកិច្ច ។ ហេតុដល់ថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០២១ កម្លាំងការិយាល័យព្រហ្មទណ្ឌបានចុះទៅកាន់ទីតាំងដី ស្ថិតនៅភូមិលៀប ឃុំពាក់ស្នែង ស្រុកបន្ទាយស្រី ខេត្តសៀមរាប បានអនុវត្តដីកាបញ្ជាឲ្យចូលខ្លួនលេខ ២១៣/២១ លេខ២១៤/២១ លេខ ២១៥/២១ និងលេខ២១៩/២១ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០២១ របស់អយ្យការអមសាលាដំបូងខេត្ត



Scanned with CamScanner

សៀមរាប បានឃាត់ខ្លួនជនសង្ស័យចំនួន៤នាក់ ឈ្មោះ [redacted] សារិន ឈ្មោះ [redacted] សេរីវឌ្ឍនៈ ឈ្មោះ [redacted] សេរីរ័ត្ន និងឈ្មោះ [redacted] គុណា ។

៦-ពេលសវនាការជនជាប់ចោទឈ្មោះ [redacted] សេង ឈ្មោះ [redacted] សារិន ឈ្មោះ [redacted] សុគុណា ឈ្មោះ [redacted] សេរីវឌ្ឍ ឈ្មោះ [redacted] សេរីរ័ត្ន និងឈ្មោះ [redacted] ឈុនឡេង បានឆ្លើយបដិសេធការចោទប្រកាន់ថាកាលពីថ្ងៃទី១៥ ខែមីនា ឆ្នាំ២០២១ រូបខ្លួនមិនមានវត្តមាននៅទីតាំងដីទំនាស់ ស្ថិតនៅភូមិលៀប ឃុំពាក់ស្នែង ស្រុកអង្គរធំ ខេត្តសៀមរាប នោះទេ ។ ដោយឈ្មោះ [redacted] សារិន ឈ្មោះ [redacted] សេរីវឌ្ឍ ឈ្មោះ [redacted] សេរីរ័ត្ន ឈ្មោះ [redacted] នឡេង បានអះអាងថានាកាលបរិច្ឆេទនោះ ពួកខ្លួនបានទៅចូលរួមញុំាការគេនៅស្រុកបន្ទាយស្រី។ ចំណែកជនជាប់ចោទឈ្មោះ [redacted] សេង បានអះអាងថាមុនមានអង្គហេតុចោទប្រកាន់កើតឡើងគឺរូបខ្លួនបានទៅសាលាឧទ្ធរណ៍បាត់ដំបង ។ ចំពោះឈ្មោះ [redacted] សុគុណា អះអាងថានាកាលបរិច្ឆេទនោះ រូបខ្លួនបានទៅចូលរួមធ្វើនំបញ្ចុកបុណ្យភូមិនៅផ្ទះឈ្មោះ [redacted] ភន និងឈ្មោះ [redacted] ពៅ ។

៧-តាមការពិនិត្យចម្លើយសាក្សីឈ្មោះ [redacted] សាភេន បានឆ្លើយថានៅថ្ងៃទី១៥ ខែមីនា ឆ្នាំ២០២១ ក្នុងចំណោមជនជាប់ចោទឈ្មោះ [redacted] សង ឈ្មោះ [redacted] សារិន ឈ្មោះ [redacted] សុគុណា ឈ្មោះ [redacted] សេរីវឌ្ឍ ឈ្មោះ [redacted] សេរីរ័ត្ន និងឈ្មោះ [redacted] ឈុនឡេង អ្នកដែលបានចូលរួមញុំាការកូនរបស់គាត់ គឺមានតែ២នាក់ មានឈ្មោះ [redacted] សារិន និងឈ្មោះ [redacted] ឈុនឡេង តាមការយល់ឃើញចម្លើយនេះបញ្ជាក់ពីការចូលរួមមានពិតប្រាកដមែន ប៉ុន្តែចំពោះម៉ោងសាក្សីនិយាយថាចូលរួមនៅម៉ោង២ ដល់ម៉ោង៦ល្ងាច មានន័យថាផ្ទុយនឹងចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] សារិន គឺខ្លួនមានគ្នា៤នាក់ មានខ្លួន កូនរបស់ខ្លួនឈ្មោះ [redacted] សេរីរ័ត្ន ឈ្មោះ [redacted] សេរីវឌ្ឍ និងឈ្មោះ ជាម ឈុនឡេង ហើយពេលវេលាឈ្មោះ [redacted] សារិន ឆ្លើយថាទៅចូលរួមម៉ោង១១ រហូតដល់ម៉ោង២រសៀល ត្រឡប់មកផ្ទះវិញ តាមកាលបរិច្ឆេទថ្ងៃកើតហេតុនៅថ្ងៃទី១៥ ខែមីនា ឆ្នាំ២០២១ មានហេតុការណ៍ចំនួន៣លើក លើកទី១វេលាម៉ោង១០ព្រឹក លើកទី២នៅម៉ោង១២ថ្ងៃត្រង់ និងលើកទី៣នៅម៉ោង៤រសៀល ដែលតាមការអះអាងរបស់សាក្សីឈ្មោះ [redacted] កុសល និងឈ្មោះ [redacted] សំបូរ បានឆ្លើយថាមានករណីមានក្រុមមនុស្សមួយក្រុម បានមកហាមឃាត់លើរូបខ្លួនដែលកំពុងភ្ជួរដី និងមើលការភ្ជួរដី ពេលនោះឈ្មោះ [redacted] សុវណ្ណ មានវត្តមាននៅទីនោះ ឈ្មោះ [redacted] យ៉ា ឈ្មោះ [redacted] ធឿប និងឈ្មោះ [redacted] ត បានប្រទូសសារាយតាមរយៈពាក្យសម្តីព្រមទាំងបានគំរាមលើពួកខ្លួន ឱ្យឈប់ភ្ជួរដី ហើយគម្រាមចាក់សាំងដុតត្រាក់ទ័រ គម្រាមសម្លាប់ និងបានចាប់ដកហូតទូរស័ព្ទរបស់ឈ្មោះ [redacted] សឿត ឈ្មោះ [redacted] ធឿប យកចេញ និងចាប់ឈ្មោះ [redacted] សុវណ្ណ ឈ្មោះ [redacted] ធឿប ព័ទ្ធស្លាបសេកដើម្បីចាប់អូសចូលឡានជិះចេញយកទៅបាត់ ។ ចម្លើយនេះស្របនឹងចម្លើយសាក្សីឈ្មោះ [redacted] ក័ក្រ សាក្សីឈ្មោះ [redacted] ប៊ុនរ៉ុង និងចម្លើយដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] សុវណ្ណ ឈ្មោះ [redacted] ធឿប ឈ្មោះ [redacted] សឿត និងឈ្មោះ [redacted] យ៉ា ។ ក្រោយពេលចាប់ឈ្មោះ [redacted] សុវណ្ណ និងឈ្មោះ [redacted] ធឿប ចូលឡានហើយបាននាំទៅស្រះឈូក ហើយឈ្មោះ [redacted] អ៊ុច បានធ្វើសកម្មភាពគំរាមកំហែង ដកហូតទូរស័ព្ទ និងបោកកំទេចអាយគូមចំនួនមួយគ្រឿង ព្រមទាំងដកហូតប្រាក់អស់ចំនួន ៤០០,០០០ (សែសិបម៉ឺន) រៀល ពីឈ្មោះ [redacted] យ៉ា ដែលមិនបានប្រគល់ត្រឡប់មកវិញឡើយ ។ សកម្មភាពរបស់ជនជាប់ចោទឈ្មោះ [redacted] សេង ឈ្មោះ [redacted] សារិន ឈ្មោះ [redacted] សុគុណា ឈ្មោះ [redacted] សេរីវឌ្ឍ ឈ្មោះ [redacted] សេរីរ័ត្ន ឈ្មោះ [redacted] ឆៃគី និងឈ្មោះ [redacted] ឈុនឡេង ជាអំពើ ពីបទ **លួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា** ពីបទ **ធ្វើឱ្យខូចខាតដោយ**



Scanned with CamScanner

ចេតនា ពីបទ **ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោស** ពីបទ **ចាប់ដោយខុសច្បាប់** ពីបទ **គំរាមកំហែងថានឹងសម្លាប់ដោយមានបញ្ជាឱ្យបំពេញលក្ខខណ្ឌ** និងពីបទ **លុបបំបាត់វត្ថុតាង** ប្រព្រឹត្តនៅភូមិលៀប ឃុំពាក់ស្នែង ស្រុកអង្គរធំ ខេត្តសៀមរាប កាលពីថ្ងៃទី១៥ ខែមីនា ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌដែលមានចែងនិងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា**៣៥៣** មាត្រា**៣៥៧** មាត្រា៤១០ មាត្រា៤១១ មាត្រា២១៨ **មាត្រា២៥៣ ចំណុច១ មាត្រា២៣៤ និងមាត្រា៥៣៣** នៃក្រមព្រហ្មទណ្ឌ ។

៨-មានកស្តុតាងដាក់បន្ទុក និងពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ [redacted]សេង ភេទប្រុស អាយុ៤១ឆ្នាំ កើតឆ្នាំ១៩៧៧ ជនជាតិខ្មែរ ជនជាប់ចោទឈ្មោះ [redacted]សារិន ភេទប្រុស អាយុ៦០ឆ្នាំ កើតនៅថ្ងៃទី៥ ខែកញ្ញា ឆ្នាំ១៩៦០ ជនជាតិខ្មែរ ជនជាប់ចោទឈ្មោះ [redacted]សុគុណា ភេទប្រុស អាយុ៣៨ឆ្នាំ កើតនៅថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៨២ ជនជាតិខ្មែរ ជនជាប់ចោទឈ្មោះ [redacted]សេរីវុឌ្ឍ ហៅ សេរីវឌ្ឍនៈ ភេទប្រុស អាយុ២៥ឆ្នាំ កើតនៅឆ្នាំ១៩៩៦ ជនជាតិខ្មែរ ជនជាប់ចោទឈ្មោះ [redacted]ឈុនឡេង ភេទប្រុស អាយុ៤៧ឆ្នាំ កើតនៅថ្ងៃទី១៥ ខែឧសភា ឆ្នាំ១៩៧៣ ជនជាតិខ្មែរ ជនជាប់ចោទឈ្មោះ [redacted]សេរីរ័ត្ន ភេទប្រុស អាយុ២៧ឆ្នាំ កើតនៅឆ្នាំ១៩៩៤ ជនជាតិខ្មែរ ជនជាប់ចោទឈ្មោះ [redacted]ឆគី ភេទប្រុស អាយុ៣២ឆ្នាំ កើតនៅឆ្នាំ១៩៨៩ ជនជាតិខ្មែរ ជនជាប់ចោទឈ្មោះ [redacted]អ៊ុច ភេទប្រុស អាយុ៤៣ឆ្នាំ កើតនៅថ្ងៃទី៧ ខែសីហា ឆ្នាំ១៩៧៩ ជនជាតិខ្មែរ ពីបទ **លួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា** ពីបទ **ធ្វើឱ្យខូចខាតដោយចេតនា** ពីបទ **ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោស** ពីបទ **ចាប់ដោយខុសច្បាប់** ពីបទ **គំរាមកំហែងថានឹងសម្លាប់ដោយមានបញ្ជាឱ្យបំពេញលក្ខខណ្ឌ** និងពីបទ **លុបបំបាត់វត្ថុតាង** ប្រព្រឹត្តនៅភូមិលៀប ឃុំពាក់ស្នែង ស្រុកអង្គរធំ ខេត្តសៀមរាប កាលពីថ្ងៃទី១៥ ខែមីនា ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌដែលមានចែងនិងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា**៣៥៣** មាត្រា**៣៥៧** មាត្រា៤១០ មាត្រា៤១១ មាត្រា២១៨ មាត្រា២៥៣ ចំណុច១ មាត្រា២៣៤ **និងមាត្រា៥៣៣** នៃក្រមព្រហ្មទណ្ឌ ។

## ហេតុដូច្នេះសម្រេច

**ក**-ផ្តន្ទាទោសជនជាប់ចោទ៖

១-ឈ្មោះ [redacted]សេង ភេទប្រុស អាយុ៤១ឆ្នាំ កើតឆ្នាំ១៩៧៧ ជនជាតិខ្មែរ **ពន្ធនាគារកំណត់រយៈពេល ០៣ (បី) ឆ្នាំ អនុវត្ត ២ (ពីរ) ឆ្នាំ ០៦ (ប្រាំមួយ) ខែ ទោសផ្សេងពីនេះត្រូវអនុវត្តការព្យួរទោសធម្មតា** ពីបទ **លួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា** ពីបទ **ធ្វើឱ្យខូចខាតដោយចេតនា** ពីបទ **ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោស** ពីបទ **ចាប់ដោយខុសច្បាប់** ពីបទ **គំរាមកំហែងថានឹងសម្លាប់ដោយមានបញ្ជាឱ្យបំពេញលក្ខខណ្ឌ** និងពីបទ **លុបបំបាត់វត្ថុតាង** ប្រព្រឹត្តនៅភូមិលៀប ឃុំពាក់ស្នែង ស្រុកអង្គរធំ ខេត្តសៀមរាប កាលពីថ្ងៃទី១៥ ខែមីនា ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌដែលមានចែងនិងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា**៣៥៣** មាត្រា**៣៥៧** មាត្រា៤១០ មាត្រា៤១១ មាត្រា២១៨ **មាត្រា២៥៣ ចំណុច១** មាត្រា២៣៤ **និងមាត្រា៥៣៣** នៃក្រមព្រហ្មទណ្ឌ ។

២-ជនជាប់ចោទឈ្មោះ [redacted]អ៊ុច ភេទប្រុស អាយុ៤៣ឆ្នាំ កើតនៅថ្ងៃទី៧ ខែសីហា ឆ្នាំ១៩៧៩ ជនជាតិខ្មែរ **ពន្ធនាគារកំណត់រយៈពេល ៣ (បី) ឆ្នាំ** ពីបទ លួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្ត



Scanned with CamScanner

អំពើហិង្សា ពីបទ **ធ្វើឱ្យខូចខាតដោយចេតនា** ពីបទ **ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោស** ពីបទ **ចាប់ដោយខុសច្បាប់** ពីបទ **គំរាមកំហែងថានឹងសម្លាប់ដោយមានបញ្ជាឱ្យបំពេញលក្ខខណ្ឌ** និងពីបទ **លុបបំបាត់វត្ថុតាង** ប្រព្រឹត្តនៅភូមិលៀប ឃុំពាក់ស្នែង ស្រុកអង្គរធំ ខេត្តសៀមរាប កាលពីថ្ងៃទី១៥ ខែមីនា ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌដែលមានចែងនិងឱ្យផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា**៣៥៣** មាត្រា**៣៥៧** មាត្រា**៤១០** មាត្រា**៤១១** មាត្រា**២១៨** មាត្រា**២៥៣ ចំណុច១** មាត្រា**២៣៤** និងមាត្រា**៥៣៣** នៃក្រមព្រហ្មទណ្ឌ ។

៣-ឈ្មោះ [redacted]**សារិន** ភេទប្រុស អាយុ៦០ឆ្នាំ កើតនៅថ្ងៃទី៥ ខែកញ្ញា ឆ្នាំ១៩៦០ ជនជាតិខ្មែរ **ពន្ធនាគារកំណត់រយៈពេល ៣ (បី) ឆ្នាំ** ពីបទ **លួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា** ពីបទ **ធ្វើឱ្យខូចខាតដោយចេតនា** ពីបទ **ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោស** ពីបទ **ចាប់ដោយខុសច្បាប់** ពីបទ **គំរាមកំហែងថានឹងសម្លាប់ដោយមានបញ្ជាឱ្យបំពេញលក្ខខណ្ឌ** និងពីបទ **លុបបំបាត់វត្ថុតាង** ប្រព្រឹត្តនៅភូមិលៀប ឃុំពាក់ស្នែង ស្រុកអង្គរធំ ខេត្តសៀមរាប កាលពីថ្ងៃទី១៥ ខែមីនា ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌដែលមានចែងនិងឱ្យផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា**៣៥៣** មាត្រា**៣៥៧** មាត្រា**៤១០** មាត្រា**៤១១** មាត្រា**២១៨** មាត្រា**២៥៣ ចំណុច១** មាត្រា**២៣៤** និងមាត្រា**៥៣៣** នៃក្រមព្រហ្មទណ្ឌ ។

៤-ឈ្មោះ [redacted]**សេរីវុឌ្ឍ ហៅ សេរីវឌ្ឍនៈ** ភេទប្រុស អាយុ២៥ឆ្នាំ កើតនៅឆ្នាំ១៩៩៦ ជនជាតិខ្មែរ **ពន្ធនាគារកំណត់រយៈពេល ៣ (បី) ឆ្នាំ** ពីបទ **លួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា** ពីបទ **ធ្វើឱ្យខូចខាតដោយចេតនា** ពីបទ **ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោស** ពីបទ **ចាប់ដោយខុសច្បាប់** ពីបទ **គំរាមកំហែងថានឹងសម្លាប់ដោយមានបញ្ជាឱ្យបំពេញលក្ខខណ្ឌ** និងពីបទ **លុបបំបាត់វត្ថុតាង** ប្រព្រឹត្តនៅភូមិលៀប ឃុំពាក់ស្នែង ស្រុកអង្គរធំ ខេត្តសៀមរាប កាលពីថ្ងៃទី១៥ ខែមីនា ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌដែលមានចែងនិងឱ្យផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា**៣៥៣** មាត្រា**៣៥៧** មាត្រា**៤១០** មាត្រា**៤១១** មាត្រា**២១៨** មាត្រា**២៥៣ ចំណុច១** មាត្រា**២៣៤** និងមាត្រា**៥៣៣** នៃក្រមព្រហ្មទណ្ឌ ។

៥-ជនជាប់ចោទឈ្មោះ [redacted]**សេរីរ័ត្ន** ភេទប្រុស អាយុ២៧ឆ្នាំ កើតនៅឆ្នាំ១៩៩៤ ជនជាតិខ្មែរ **ពន្ធនាគារកំណត់រយៈពេល ៣ (បី) ឆ្នាំ** ពីបទ **លួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា** ពីបទ **ធ្វើឱ្យខូចខាតដោយចេតនា** ពីបទ **ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោស** ពីបទ **ចាប់ដោយខុសច្បាប់** ពីបទ **គំរាមកំហែងថានឹងសម្លាប់ដោយមានបញ្ជាឱ្យបំពេញលក្ខខណ្ឌ** និងពីបទ **លុបបំបាត់វត្ថុតាង** ប្រព្រឹត្តនៅភូមិលៀប ឃុំពាក់ស្នែង ស្រុកអង្គរធំ ខេត្តសៀមរាប កាលពីថ្ងៃទី១៥ ខែមីនា ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌដែលមានចែងនិងឱ្យផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា**៣៥៣** មាត្រា**៣៥៧** មាត្រា**៤១០** មាត្រា**៤១១** មាត្រា**២១៨** មាត្រា**២៥៣ ចំណុច១** មាត្រា**២៣៤** និងមាត្រា**៥៣៣** នៃក្រមព្រហ្មទណ្ឌ ។

៦-ជនជាប់ចោទឈ្មោះ [redacted]**ឈុនឡេង** ភេទប្រុស អាយុ៤៧ឆ្នាំ កើតនៅថ្ងៃទី១៥ ខែឧសភា ឆ្នាំ១៩៧៣ ជនជាតិខ្មែរ **ពន្ធនាគារកំណត់រយៈពេល ៣ (បី) ឆ្នាំ** ពីបទ **លួចមានស្ថានទម្ងន់ទោសដោយ**

សារការប្រព្រឹត្តអំពើហិង្សា ពីបទ **ធ្វើឱ្យខូចខាតដោយចេតនា** ពីបទ **ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោស** ពីបទ **ចាប់ដោយខុសច្បាប់** ពីបទ **គំរាមកំហែងថានឹងសម្លាប់ដោយមានបញ្ជាឱ្យបំពេញលក្ខខណ្ឌ** និងពីបទ **លុបបំបាត់វត្ថុតាង** ប្រព្រឹត្តនៅភូមិលៀប ឃុំពាក់ស្នែង ស្រុកអង្គរធំ ខេត្តសៀមរាប កាលពីថ្ងៃទី១៥ ខែមីនា ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌដែលមានចែងនិងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា**៣៥៣** មាត្រា៣៥៧ មាត្រា៤១០ មាត្រា៤១១ មាត្រា២១៨ **មាត្រា២៥៣ ចំណុច១ មាត្រា២៣៤ និងមាត្រា៥៣៣** នៃក្រមព្រហ្មទណ្ឌ ។

៧-ជនជាប់ចោទឈ្មោះ [redacted] សុគុណ ភេទប្រុស អាយុ៣៨ឆ្នាំ កើតនៅថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៨២ ជនជាតិខ្មែរ **ពន្ធនាគារកំណត់រយៈពេល ៣ (បី) ឆ្នាំ** ពីបទ **លួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា** ពីបទ **ធ្វើឱ្យខូចខាតដោយចេតនា** ពីបទ **ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោស** ពីបទ **ចាប់ដោយខុសច្បាប់** ពីបទ **គំរាមកំហែងថានឹងសម្លាប់ដោយមានបញ្ជាឱ្យបំពេញលក្ខខណ្ឌ** និងពីបទ **លុបបំបាត់វត្ថុតាង** ប្រព្រឹត្តនៅភូមិលៀប ឃុំពាក់ស្នែង ស្រុកអង្គរធំ ខេត្តសៀមរាប កាលពីថ្ងៃទី១៥ ខែមីនា ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌដែលមានចែងនិងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា**៣៥៣** មាត្រា**៣៥៧** មាត្រា៤១០ មាត្រា៤១១ មាត្រា២១៨ **មាត្រា២៥៣ ចំណុច១ មាត្រា២៣៤ និងមាត្រា៥៣៣** នៃក្រមព្រហ្មទណ្ឌ ។

៨-ជនជាប់ចោទឈ្មោះ [redacted] ផៃគី ភេទប្រុស អាយុ៣២ឆ្នាំ កើតនៅឆ្នាំ១៩៨៩ ជនជាតិខ្មែរ ដាក់ពន្ធនាគារកំណត់រយៈពេល ៣ (បី) ឆ្នាំ ពីបទ **លួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា** ពីបទ **ធ្វើឱ្យខូចខាតដោយចេតនា** ពីបទ **ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោស** ពីបទ **ចាប់ដោយខុសច្បាប់** ពីបទ **គំរាមកំហែងថានឹងសម្លាប់ដោយមានបញ្ជាឱ្យបំពេញលក្ខខណ្ឌ** និងពីបទ **លុបបំបាត់វត្ថុតាង** ប្រព្រឹត្តនៅភូមិលៀប ឃុំពាក់ស្នែង ស្រុកអង្គរធំ ខេត្តសៀមរាប កាលពីថ្ងៃទី១៥ ខែមីនា ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌដែលមានចែងនិងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា**៣៥៣** មាត្រា**៣៥៧** មាត្រា**៤១០** មាត្រា៤១១ មាត្រា២១៨ **មាត្រា២៥៣ ចំណុច១ មាត្រា២៣៤ និងមាត្រា៥៣៣** នៃក្រមព្រហ្មទណ្ឌ ។

**ខ**-បង្គាប់ឱ្យឈ្មោះ [redacted] អ៊ិច ឈ្មោះ [redacted] សារិន ឈ្មោះ [redacted] សេង ឈ្មោះ [redacted] ឈុនឡេង ឈ្មោះ [redacted] សេរីវត្ថ ឈ្មោះ [redacted] សេរីវុឌ្ឍ ឈ្មោះ [redacted] សុគុណ និងឈ្មោះ [redacted] ផៃគី រួមគ្នាសងសំណងជម្ងឺចិត្ត និងការខូចខាតទៅដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] សុវណ្ណ ឈ្មោះ [redacted] ចឿប និងឈ្មោះ [redacted] សឿត ក្នុងម្នាក់ៗចំនួន ២០,០០០,០០០ (ម្ភៃលាន) រៀល ។

**គ**-បង្គាប់ឱ្យឈ្មោះ [redacted] សារិន សងសំណងជម្ងឺចិត្ត និងការខូចខាតទៅដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ យឿន យ៉ា ចំនួន ២,០០០,០០០ (ពីរលាន) រៀល ។

-សាលក្រមនេះជំនុំជម្រះចំពោះមុខជនជាប់ចោទឈ្មោះ [redacted] សារិន ឈ្មោះ [redacted] សេង ឈ្មោះ [redacted] ឈុនឡេង ឈ្មោះ [redacted] សេរីវត្ថ ឈ្មោះ [redacted] សេរីវុឌ្ឍ ឈ្មោះ [redacted] សុគុណ ចំពោះមុខដើមបណ្តឹងរដ្ឋប្បវេណី



Scanned with CamScanner

ឈ្មោះ [redacted] សុវណ្ណ ឈ្មោះ [redacted] សឿត ឈ្មោះ [redacted] ថឿប ឈ្មោះ [redacted] យ៉ា កំបាំងមុខជនជាប់ចោទ ឈ្មោះ [redacted] ឆៃគី ឈ្មោះ [redacted] អ៊ុច និងប្រកាសជាសាធារណៈនៅថ្ងៃទី៣០ ខែសីហា ឆ្នាំ២០២៣ ពេលព្រឹក។

-ទុកសិទ្ធិប្តឹងទាស់ និងប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់។

| | |
|---|---|
| **ក្រឡាបញ្ជីសវនាការ** | **ចៅក្រមជំនុំជម្រះ** |
| ហត្ថលេខា និងត្រា: [redacted] | ហត្ថលេខា និងត្រា: [redacted] |

---

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

ថ្ងៃពុធ ១៤កើត ខែស្រាពណ៍ ឆ្នាំថោះ បញ្ចស័ក ព.ស ២៥៦៧

ធ្វើនៅសៀមរាប,ថ្ងៃទី៣០ ខែសីហា ឆ្នាំ២០២៣

**ក្រឡាបញ្ជីសវនាការ**

[redacted]

បានឃើញ

**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

[redacted]